# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### កំណត់ហេតុកិច្ចប្រជុំពិភាក្សា ពិគ្រោះយោបល់

ស្តីពី

របាយការណ៍ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង លើគំរោងស្នើសុំ ធ្វើអាជីវកម្មស្រាវជ្រាវរុករករ៉ែ របស់ក្រុមហ៊ុន Samnang Rea Thborng Thmor Import-Export and Development CO., LTD. ស្ថិតនៅតំបន់អូរតាគុត ស្រុកថ្មបាំង និងស្រុកស្រែអំបិល ខេត្តកោះកុង

កាលពីវេលាម៉ោងប្រាំបីសាមសិបនាទី ថ្ងៃទី ដប់ប្រាំមួយ ខែ តុលា ឆ្នាំ ពីរពាន់ប្រាំបួន នៅសាលាខេត្តកោះកុង មានបើកកិច្ចប្រជុំពិភាក្សាមួយលើបទបង្ហាញរបាយការណ៍ស្តីពី ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង លើគំរោងស្នើសុំធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែ អ៊ីលម៉េនីត (Ilmenite) នៅតំបន់អូរតាគុត ស្រុកថ្មបាំង និងឃុំជីខលើស្រុកស្រែអំបិល ខេត្តកោះកុង របស់ក្រុមហ៊ុន Samnang Rea Thborng Thmor Import-Export and Development CO., LTD. ក្រោមអធិបតីភាព **ឯកឧត្តម សុន តារា** អភិបាលរងខេត្តកោះកុង។

សមាសសភាពអញ្ជើញចូលរួមមាន៖

| | | |
|---|---|---|
| ១- លោក | ប៉ែន ស៊ីណា | អគ្គលេខាធិការ សាលាខេត្ត |
| ២- លោក | ផន គីមកន | នាយរងក្រុមអធិការកិច្ច សាលាខេត្ត |
| ៣- បណ្ឌិត | លី សុពណ៌-មុនី | នាយក **GCF** (Green Consultancy Firm |
| ៤- លោក | លឹម សាវ៉ាន់ | នាយខុទ្ទកាល័យស្តីទី |
| ៥- លោក | សៅ ស៊ីនធូន | នាយរងខុទ្ទកាល័យ |
| ៦- លោក | ប៊ិច ស៊ីយុន | ប្រធានមន្ទីរមន្ទីរឧស្សាហកម្ម |
| ៧- លោក | មាស ស៊ីថា | នាយរងខណ្ឌរដ្ឋបាលព្រៃឈើ |
| ៨- លោក | ជៃ ពេជរតនា | ប្រធានមន្ទីរបរិស្ថាន |
| ៩- លោក | ប៊ុន លើក | អភិបាលស្រុកស្រែអំបិល |



Draft

១០- លោក ទូ សារុំថ អភិបាលស្រុកថ្មបាំង
១០- លោក ឡៅ សារុំន បុគ្គលិក **GCF** (Green Consultancy Firm )
១២-លោក ឈេង សុវណ្ណដា មន្ត្រីការិយាល័យសរុបខេត្ត
១៣-លោក **Romica Grosu** មន្ត្រីមកពីអង្គការ **Wildlife Alliance**
១៤- លោក ហ៊ត់ សុគន្ធ មន្ត្រីសម្របសម្រួលអង្គការសម្ព័ន្ធមិត្តសត្វព្រៃ

ជាកិច្ចចាប់ផ្ដើមឯកឧត្ដម **សុន នារា** អភិបាលរងខេត្តកោះកុងមានមតិសំណេះសំណាល និងថ្លែងបើកអង្គប្រជុំអោយដំណើរការរួមមានខ្លឹមសារដូចតទៅ :

**បណ្ឌិត លី សុពណ៌-មុនី** : ថ្ងៃនេះខ្ញុំរីករាយណាស់ដែលឯកឧត្តមបានអនុញ្ញាតឱ្យក្រុមហ៊ុនយើងខ្ញុំ ធ្វើបទបង្ហាញទៅលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម លើគំរោងស្នើសុំធ្វើអាជីវកម្មសាវជ្រាវ និងរុករកសំបុករ៉ែ អ៊ីលម៉េនីត (Ilmenite) របស់ក្រុមហ៊ុន Samnang Rea Thborng Thmor Import-Export and Development CO., LTD.ស្ថិតនៅតំបន់អូរតាគុត ស្រុកថ្មបាំង និងស្រុកស្រែអំបិល ខេត្តកោះកុង។ ក្រុមហ៊ុននេះមានព្រំប្រទល់ខាងជើងឈាងខាងលិចជាប់ និងឃុំថ្មដូនពៅ ឃុំជំនាប់ស្រុកថ្មបាំង និងឃុំជីខលើ ខាងកើតជាប់ព្រំប្រទល់ឃុំដងពែង ស្រុកស្រែអំបិល ឯខាងលិចជាប់នឹង ព្រំប្រទល់ និងឃុំជំនាប់ ក្នុងស្រុកថ្មបាំង និងស្រុកស្រែអំបិល។ ចំពោះចំណុចនិយាមកា និងទីតាំង ភូមិសាស្ត្រ ខ្ញុំមិនចាំបាច់និយាយទៀតទេ គឺសូមលើកយកបទដ្ឋានច្បាប់របស់ក្រុមហ៊ុនសំណាងរ៉ែ តើក្រុមហ៊ុន សំណាងរ៉ែ មានអាទិភាពច្បាប់យ៉ាងណាខ្លះ ដើម្បីចុះទៅសិក្សាស្រាវជ្រាវ និងឈានធ្វើអាជីវកម្មរ៉ែនៅក្នុងឆ្នាំខាងមុខ ខ្ញុំនិង អធិប្បាយដូចតទៅនេះ ។

-តាមរយៈលិខិតលេខ ១២៦២ ឧរថ ចុះថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ស្ដីពីអាជ្ញាបណ្ណ័ស្វែងរុករករ៉ែ បន្ទាប់មកទៀតពាក់ពន្ធ័ទៅនឹង អានុសារណៈស្ដីពីការសិក្សា ស្វែងយល់ជំរករ៉ែ (ILMENITE) នៅតំបន់អូរតាគុត ស្រុកថ្មបាំង ខេត្តកោះកុង ធ្វើឡើងនៅឆ្នាំ ២០០៤ រវាងក្រសួងឧស្សាកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុនសំណាងរ៉ែ ត្បូងថ្ម អាហ័រណ-នីហ័រណ ដែលចុះហត្ថលេខានៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០០៥ ដោយ **ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាកម្ម រ៉ែ និងថាមពល និង លោក **សាវ ឈុនសុង** ប្រធានក្រុមហ៊ុន សំណាងរ៉ែ ត្បូងថ្ម និងអភិវឌ្ឍន៏។ ហើយក្នុងនោះដែលក៏មាន

-កិច្ចព្រមព្រៀងស្តីពីការស្រាវជ្រាវរ៉ែអ៊ីលម៉ានីត (ILMENITE) នៅតំបន់អូរតាគុត ស្រុកថ្មបាំង ធ្វើឡើងនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០៥ រវាងរវាងក្រសួងឧស្សាកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុនសំណាងរ៉ែ ត្បូងថ្ម អាហ័រណ-នីហ័រណ ដែលចុះហត្ថលេខានៅថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ២០០៥ ដោយ **ឯកឧត្តម**



Draft

**ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល និង លោក **សារ៉ ឈុនសុង** ប្រធានក្រុមហ៊ុន សំណាងរ៉ែត្បូងថ្ម និងអភិវឌ្ឍន៍ ។

បន្ទាប់ទៅទៀតនេះ តើយើងធ្វើយ៉ាងណាដើម្បីវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ប្រសិនបើមានការធ្វើអាជីវកម្មរ៉ែនៅក្នុងតំបន់នោះ ។ យើងកំណត់ទៅលើចំណុចសខាន់៣ គឺៈ(១)ការងារសិក្សាធនធានរូបវន្ត និងការអង្កេតអេកូឡូស៊ី (២) ការងារសិក្សាធនធានសង្គម សេដ្ឋកិច្ចនៃតំបន់គំរោង (៣) ការងារពិនិត្យការប្រើប្រាស់ដី និងវាយតំលៃស្ថានភាពគំរបព្រៃដោយប្រើ ឧបករណ៍ Paramotor បច្ចុប្បន្នដោយសារថាយើងស្ថិតនៅក្នុងរដូវវស្សានៅឡើយ និងទីតាំងរបស់ក្រុមហ៊ុនសំណាងរ៉ែនោះស្ថិតនៅចម្ងាយ១៦គ.ម ភាគខាងជើងទីរួមស្រុកថ្មបាំងម្យ៉ាងទៀតផ្លូវគមនាគមន៍ពិបាក បើយើងទៅផ្លូវមួយទៀតដោយអូបរ័ឡើងតាមព្រែកស្រុកស្រែអំបិលប្រើរយៈពេលប្រហែលជា ៣ម៉ោង រួចហើយចុះដើរចម្ងាយ១០ គ.មទៀតបានទៅដល់ការដ្ឋាននោះ ។ ហើយដោយសារភូមិសាស្ត្រវាពិបាកនៅក្នុងរដូវវស្សា ការអង្កេតអេកូឡូស៊ីដោយសារធ្វើ Grown Surveyក៏មិនអាចធ្វើបានដែរ ។ ម្យ៉ាងទៀតការសិក្សាដោយការហោះហើរពិនិត្យទៅលើគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់គំរោងក៏មិនអាចធ្វើបាន ដូចឯកឧត្តមអស់លោក លោកស្រី ដែលជាស្ថាប័ពាក់ពន្ធ័ជ្រាបស្រាប់ហើយ ប៉ុន្មានថ្ងៃចុងក្រោយមេឃស្រឡះបន្តិច ក៏ប៉ុន្តែនៅតំបន់នោះនៅមានពពកច្រើននៅឡើយ ។ ដូច្នេះការអង្កេតពីលើអាកាសពិតជាមិនអាចប្រព្រឹត្តទៅបានទេ យើងត្រូវរង់ចាំចុងខែនេះ ឬពាក់កណ្តាលខែក្រោយទើបការអង្កេតពីលើអាកាសអាចធ្វើទៅបាន ជាពិសេសដូចមានឯកឧត្តមថ្នាក់ដឹកនាំខែមានវត្តមាននៅទីនេះស្រាប់ នេះគ្រាន់តែជួបលើកដំបូងរវាងក្រុមការងារបច្ចេកទេជាមួយនឹងថ្នាក់ដឹកនាំដើម្បីពិគ្រោះយោបល់តែប៉ុណ្ណោះ ។ ប៉ុន្តែ ចប់ពីនេះទៅរបាយការណ៍នេះត្រូវចងក្រងឱ្យបានសព្វគ្រប់ហើយដាក់ប្រជុំនៅក្រសួងបរិស្ថានចំនួន៣ដងទៀត លើកទី១យើងប្រជុំឆ្លងថ្នាក់នាយកដ្ឋានបច្ចេកទេស លើកទី២ប្រជុំឆ្លងថ្នាក់ដឹកនាំក្រសួងបរិស្ថាន ហើយប្រជុំលើកទី៣សំរេចចុងក្រោយនោះគឺប្រជុំថ្នាក់អន្តរក្រសួង ។ ដូច្នេះនេះគ្រាន់តែជាការជួបគ្នាលើកដំបូង ទោះពតិមានការពាក់ជាមួយការអង្កេតអេកូឡូស៊ុ ហើយនិងការអង្កេតពីលើអាកាសពុំទាន់បានប្រព្រឹត្តទៅក្តី ខ្ញុំគិតថាឯកឧត្តមថ្នាក់ដឹកនាំលោកនឹងចូលរួមនៅពេលចុងក្រោយ ។ ដូចនេះយើងនឹង Debate គ្នាទៀតក្នុងករិតបច្ចេកទេសលំអិតនៅពេលក្រោយ ។ ជាបន្តទៅទៀតយើងសិក្សាទៅ Databases ផែនទី៤ជំនាន់ផ្សេងៗគ្នា ឆ្នាំ ១៩៩២-៩៣, ឆ្នាំ១៩៩៧ ,ឆ្នាំ២០០២ និងឆ្នាំ ២០០៦ ។

Draft

មុននឹងចូលទៅដល់ផែនទីប្រើប្រាស់ដី និងគំរបព្រៃយើងលើកយកផែនទីភូគព្ភសាស្ត្រ នៅលើផ្ទៃដីជាង ៧០០០ ហិកតា បើយើងសិក្សាអំពីភូគព្ភសាស្ត្របានន័យថា យើងសិក្សាពីសីលាមេដែលកកើតនៅក្នុងតំបន់នឹងតើសីលាមេប្រភេទជាអ្វី ? ភាគច្រើនកើតមាន Sandstone បានន័យថា ថ្មខ្សាច់មានរហូតទៅដល់ ៧៣៨៨ ហិកតា ស្មើនិង ៩៨,៥០ % ឯដីទំនាបមានលក្ខណៈលិចទឹកសីលាមេមាន ៥៩៨,៧ហិកតា ស្មើ០,៧៨ % និង

No Classified rock ៥៣.៤ហិកតា ស្មើនឹង ០.៧១% ។ ដូចឯកឧត្តម អស់លោកជ្រាបស្រាប់ហើយផែនទីភូគព្ភសាស្ត្រដែលក្រុមហ៊ុនសំណាងរ៉ែ ស្នើសុំសីលាមេមានពណ៌បែបនេះ ពណ៌លឿងនឹងគឺ Sandstone ឯពណ៌ខ្មៅនេះគឺ យើងហៅ No Classified rock ហើយនៅកន្លែងពណ៌បៃតងនេះគឺ Floodplains ដោយសារថានៅពេល ដែលព្រែកស្រែអំបិលយើងឡើងទៅបានជាដីនេះមានលក្ខណៈជាដីលិចទឹក ។

ជាបន្តទៅទៀតអ្វីដែលជាការចាប់អារម្មណ៍របស់បងរដ្ឋបាលព្រៃឈើ ហើយលោកដែលជាតំណាង Wild Aids យើងសិក្សាអំពីការប្រើប្រាស់ដី និងគំរបព្រៃ តើការប្រែប្រួលរវាងឆ្នាំ ១៩៩២-៩៣ រហូតមកដល់ឆ្នាំ២០០៦ តើគំរបព្រៃ និងការប្រើប្រាស់ដីនៅតំបន់នោះមានប្រែប្រួលយ៉ាងដូចម្តេច នេះគឺ Databases របស់យើងបានមកពី UNDP ឆ្នាំ១៩៩២-៩៣ នៅលើផ្ទៃដី៧០០០ហិកតាជាងនេះ ភាគច្រើនគ្របដណ្តប់ទៅដោយព្រៃ ប៉ុន្តែ នៅឆ្នាំ១៩៩២-៩៣ យើងគ្រាន់តែបែងចែកដីមានគំរបព្រៃ និងដីគ្មានគំរបព្រៃតែប៉ុណ្ណឹងទេ បើមើលទៅដី រហូតទៅដល់សឹងតែ ៩៩% ដែលគ្រប់ដណ្តប់ទៅដោយព្រៃ ។ ប្រសិនបើយើងមើលនៅឆ្នាំ៩៦-៩៧ តើស្ថានភាពព្រៃមានការផ្លាស់ប្តូរយ៉ាងដូចម្តេច? ដីដែលមានគំរបព្រៃមួយចំនួនជាពិសេសយើងមើលទៅព្រៃបៃតង ព្រៃស្រោង ហើយព្រៃស្រោងមួយចំនួនត្រូវបាត់បង់ ហើយវាកើតមានទៅជាព្រៃផ្សេងៗទៀតអាចទៅជាព្រៃល្បោះ ឬមួយទៅជាវាលស្មៅ។ ជាបន្តទៅទៀត ខ្ញុំ និងជំរាបជូនអំពីទំហំព្រៃដែលមានការធ្លាក់ចុះវាមានទំហំប៉ុណ្ណា ឥឡូវនេះខ្ញុំបង្ហាញពីរូបភាពសិន ។

-យើងមើលរូបភាពឆ្នាំ២០០២ ស្ថានភាពព្រៃមានការប្រែប្រួលបែបហ្នឹង ចំណែកឯឆ្នាំ២០០៦ វាមានលក្ខណៈបែបនេះ យើងនឹងបង្ហាញជូនផែនទីមួយទៀតនៅលើផ្ទៃដីជា៧០០០ហិកតា តើវាមានអ្វីខ្លះ យើងពិនិត្យឃើញដីដែលពាក់ពន្ធ័ជាមួយនឹង វ៉ាល់អេដ មានពីរ ទី១គឺស្ថិតនៅជ្រុងខាងជើងឈាងខាងលិចមានផ្ទៃដីទំហំប្រហែលជា៣៨ហិកតា ពាក់ពន្ធ័ទៅនឹងមជ្ឈមណ្ឌលភ្នំក្រវាញ (Center Cardamoms) ចំណែកឯចំណុចដែលមានពណ៌ផ្កាឈូកនេះ គឺវាពាក់ពន្ធ័ទៅនឹងសហគមន៍ព្រៃឈើដែលយើងកំណត់អាទិភាពទី១០ ដែលមានទំហំ ៨០០ហិកតាជាង ។ ហើយតទៅយើងនឹងបង្ហាញអំពីដំណើរការប្រែប្រួលនោះយ៉ាងណា? នេះគឺគំរបព្រៃនៅឆ្នាំ ១៩៩២-៩៣ ដីមានគំរបព្រៃមាន ៩៩.៩៨ % ដីវាលស្មៅមានតែ ០.០២% គឺស្មើ១.៣ ហិកតាទេ។ ចំណែកឯឆ្នាំ១៩៩៧ ប្រមាណជា៤-៥ឆ្នាំក្រោយ ផ្ទៃដីមានគំរបព្រៃបានធ្លាក់ចុះប្រមាណជា៣០% ហើយដីដែលនិយាយថា ពីមុនមកអាចជាព្រៃស្រោងក៏ដូរមកជាព្រែកម្លោត នៅក្នុងដំណាក់កាលនិមួយៗការធ្វើចំណាត់ថ្នាក់ព្រៃអាចមានលក្ខណៈផ្សេងៗគ្នា ខ្ញុំគិតថាគិតនៅកន្លែងនេះព្រែកម្លោតមិនមានទេ វាអាចថានៅពេលដែលយើងដកឈើដែលមានតំលៃពាណិជ្ជកម្មចេញ ហើយដូច្នេះវាអាចប្រែក្លាយព្រៃស្រោងទៅជាព្រៃពាក់កណ្តាលស្រោង ឬមួយទៅជាព្រៃល្បោះវិញ។ ហើយចំណែកឯដីព្រែកម្លោតវាកើនឡើងរហូតទៅជាង២០០០ហិកតាស្មើនិង២៥% ហើយដីវាលស្មៅមាន១.៣ហិតា វាឡើងមក ៣០៤ហិកតា ។ នៅឆ្នាំ២០០២ ដីមានគំរបព្រៃមានការប្រែប្រួលតិចតួច ពោលគឺពីចន្លោះ ៧០-៧៦% បានន័យថាកើនឡើងបន្តិចវិញ ព្រែកម្លោតធ្លាក់ចុះចំណែក

ផ្ទៃដីវាលស្មៅវាកើនឡើងវិញ ពី៤មក៦% ។ នៅឆ្នាំ២០០៦ គឺជា Databases ចុងក្រោយរបស់យើង ឃើញថា ផ្ទៃដីព្រៃស្រោងបន្តធ្លាក់ចុះទៀតពី៥០០០ហិកតាជាង មកនៅត្រឹម ៤០០០ហិកតាជាង ស្មើង៥៦% ព្រៃពាក់កណ្តាលស្រោងមាន១៤% ឬស្មើនឹង ១០០០ហិកតា ដីព្រៃល្បោះមាន២០០០ហិកតា ឬស្មើនឹង ១៤០% ដីព្រៃផ្សេងៗ និងដីគ្មានគំរបព្រៃ មានតែ ១២ទៅ ៦០ហិកតាទេ ឬស្មើនិង ០.១៧ ទៅ ០.៨១% ។

ធនធានសង្គមនិង សេដ្ឋកិច្ច ដោយសារថា ទីតាំងដែលក្រុមហ៊ុនសំណាងរ៉ែ ត្បូងថ្មស្នើសុំនេះគឺភាគច្រើនស្ថិតនៅឆ្ងាយ គឺ១៦គ.ម ខាងជើងទីប្រជុំជនថ្មបាំង ហើយនិងប្រមាណជាង៤០គ.មពីប្រជុំជនស្រុកស្រែអំបិល។ ដូច្នេះផលដែលពាក់ពន្ធ័ទៅនឹងប្រជាជនមានភាគតិចមែនទែន គ្មានបងប្អូនប្រជាជនណាទៅធ្វើចំការឬក៏ស្រែ ឬក៏ចំការពនេរចរនៅក្នុងតំបន់នោះទេ ហេតុនេះយើងមិនចាំបាច់លើកយកមកបកស្រាយអ្វីទេ។ ជាបន្ទាប់ទៅទៀតយើងត្រូវសិក្សាថា តើការធ្វើអាជីវកម្មរ៉ែនោះវាប៉ះពាល់អ្វីខ្លះទៀត ។

យើងនិយាយអំពីការស្រាវជ្រាវ និងរុករករ៉ែសិន មធ្យោបាយរបស់ក្រុមហ៊ុននៅរយៈពេល៤ឆ្នាំចុងក្រោយនៃការសិក្សា គាត់បានប្រើ វិស្វករបរទេស ០៥នាក់ , កម្ពុជា ០២ នាក់ , អ្នកស្គាល់ភូមិសាស្ត្រមូលដ្ឋាន ០២នាក់, កម្លាំងសន្តិសុខ ១២ នាក់ និងអ្នកដាំស្ល ០២នាក់។ ហើយឧបករណ៍ដែលគាត់ប្រើប្រាស់នោះគឺមាន ម៉ាស៊ីនខួងរ៉ែ ០២ គ្រឿង, គ្រឿងចក្រសម្រាប់ឈូស (រុញ) ព្រៃ និងដី ០១គ្រឿង គ្រឿងចក្រសម្រាប់កាយដី ០១គ្រឿង និងត្រាក់ទ័រ ០១គ្រឿង រយៈពេលនៃការស្រាវជ្រាងគឺតាំងពីខែ ឧសភា ឆ្នាំ២០០៥ រហូតមកដល់ឥឡូវ រយៈពេល៤ឆ្នាំ។ វិធីសាស្ត្រនៃការស្រាវជ្រាវរ៉ែមិនថាតែនៅកម្ពុជាទេ គឺនៅកន្លែងប្រទេសណាៗ គឺដូចគ្នាទាំងអស់។ យើងត្រូវប្រើវិធីសាស្ត្របូរាណបូក និងវិទ្យាសាស្ត្របច្ចេកវិជ្ជាទំនើប វិធីសាស្ត្របុរាណការជីកការខួងមើលអំពីវត្តមានរបស់រ៉ែ អំពីជម្រៅរបស់រ៉ែ ហើយបន្ទាប់មកទៀតយើងប្រើ Modern Technology ជាទូទៅយើងមើលពីផ្កាយរណប ដោយសារគេបាញ់មាញ៉េទិចមក អញ្ចឹងរូបភាព Color ដែលឱ្យមកនេះ គឺយើងអាចវិភាគថារ៉ែមានជម្រៅប៉ុន្មានម៉ែត្រ ប៉ុន្មានរយម៉ែត្រ ហើយស្រទាប់និមួយៗមានជម្រៅប៉ុន្មានរយម៉ែត្រ។ ដូច្នេះ វិធីសាស្ត្រដែល យើងប្រើប្រាស់នឹង Modern Industrial Scanning Fly ទៅលើរូបភាពផ្កាយរណប គេប្រើកម្មវិធី(Program)មួយឈ្មោះថា Malty Color ដើម្បីបង្ហាញអំពីស្រទាប់ហើយនិងកំរិតរបស់រ៉ែ ។

លទ្ធផលនៃការស្រាវជ្រាវ តើរ៉ែនៅតំបន់នោះមានប៉ុន្មានស្រទាប់ ហើយស្រទាប់និមួយៗមានជម្រៅប៉ុន្មាន។ តាមរយៈ Industrial Cutting Fly គឺយើងបានពិនិត្យឃើញថា រ៉ែសរុបមាន១០ស្រទាប់ ស្រទាប់ទី១មានជម្រៅ ១០០ម៉ែត្រ ខាងក្រោមនីវូសមុទ្រ ដែលមានរ៉ែសរុប ៧០៧២៦តោន ស្រទាប់ទី២ មានជម្រៅ ៥០ម៉ែត្រ ក្រោមនីវូសមុទ្រ មានបរិមាណរ៉ែសរុបចំនួន ៥៥០.០០០តោន ស្រទាប់ទី៣ ស្ថិតនៅជម្រៅស្មើនីវូសមុទ្រ មានបរិមាណរ៉ែ ២០៦.០០០តោន ស្រទាប់ទី៤ នៅជម្រៅ ៥០ម៉ែត្រ លើនីវូសមុទ្រ មានបរិមាណរ៉ែសរុបចំនួន ៤០៣.០០០តោន ស្រទាប់ទី៥ នៅជម្រៅ ១០០ម៉ែត្រលើនីវូសមុទ្រ មានបរិមាណរ៉ែសរុប ៣៥៧

.000តោន ស្រទាប់ទី៦ មានជម្រៅ ១៥០ម៉ែត្រ ខាងលើនីវ៉ូសមុទ្រមានបរិមាណរ៉ែចំនួន ៣២000 តោន ស្រទាប់ទី៧ ស្ថិតនៅជម្រៅ ២00ម៉ែត្រខ្ពស់ជាងនីវ៉ូសមុទ្រ មានរ៉ែ ២៨៧.000តោន ស្រទាប់ទី៨ ស្ថិតនៅជម្រៅ ២៥0 ម៉ែត្រ ១៥៥.000តោន ស្រទាប់ទី-៩ ស្ថិតនៅជម្រៅ៣00ម៉ែត្រ ខ្ពស់ជាងនីវ៉ូសមុទ្រ មានបរិមាណរ៉ែសរុប ចំនួន ៧៤.៦0៤តោន ស្រទាប់ទី-១០ ស្ថិតនៅជម្រៅ៣៥0ម៉ែត្រ ខ្ពស់ជាងនីវ៉ូសមុទ្រ មាននៅលើកំពូលភ្នំ បរិមាណរ៉ែសរុប តែចំនួន ២៨.៤៧0តោន ដូច្នេះបរិមាណរ៉ែសរុបដែលមាននៅក្នុងតំបន់យើងនេះគឺមាន ២.៤៣៥.000តោន ។ ចំណុចបន្ទាប់មកទៀតក្រុមហ៊ុនមានផែនការអាជីវកម្មរ៉ែ ដូចម្តេចខ្លះ?

ដោយសារការវិនិយោគទៅលើអាជីកម្មរ៉ែប្រើប្រាស់លុយច្រើន ដូចនេះក្រុមហ៊ុនគ្រោង និងធ្វើជាជំហ៊ាន៧ ។ ជំហ៊ានទី១ក្រុមហ៊ុនគ្រោង និងធ្វើនៅតំបន់ចំនួន៣ដែលមានផ្ទៃដីសរុបចំនួន១៦00ហិកតា ស្មើនឹង ១៦គីឡូម៉ែត្រក្រឡាមានបង្ហាញជូនដូចខាងក្រោមៈ

-កន្លែងទី១តំបន់អូរតាគុតៈ មានទំហំ0៤គ.ម$^{2}$ ស្មើ៤00ហិកតា ដែលមានចំណុចនិយាមកា ក-៣៥៣000 ១២៧ 0000 ខ-៣៥៥000 ១២៧0000 គ -៣៥៥000 ១២៦៨000 និង ឃ-៣៥៣000 ១២៦៨000 ។

-កន្លែងទី២តំបន់ IMN-1 មានទំហំ 0៦គ.ម$^{2}$ ស្មើ៦00ហិកតា ដែលមានចំណុចនិយាមកា ក-៣៥៥000 ១២៧0000 ខ-៣៥៧ 000 ១២៧0000 គ-៣៥៧000 ១២៦៧000 និង ឃ-៣៥៥000 ១២៦៧000 ។

-កន្លែងទី៣តំបន់ IMN-2 មានទំហំ0៦គ.ម$^{2}$ ស្មើនឹង៦00ហិកតា ដែលមានចំណុចនិយាមកា ក-៣៥៦000 ១២៧0000 ខ-៣៥៨ 000 ១២៧0000 គ-៣៥៨000 ១២៧៣000 និង ឃ-៣៥៦000 ១២៧៣000 ។

ការកំណត់សក្តានុពលអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម យើងបានបញ្ជូនក្រុមការងារចំនួន៣ក្រុម ដើម្បីចុះទៅ សិក្សាវាយតំលៃហេតុប៉ពាល់បរិស្ថាន នៅក្នុងតំបនោះក្រោមកិច្ចសន្យាផ្តល់សេវាកម្មលេខ ងចថ.សា-0៨-0៣.0៧ ជាមួយ ក្រុមហ៊ុន Samnang Rea Thborng Thmor Import-Export and Development Co., Ltd ។ ដោយពិនិត្យឃើញថា ធនធានអេកូឡូស៊ីតំបន់នេះ មិនទាន់ទទួលរងការរិចរិល និងម្យ៉ាងទៀតតំបន់សម្បទានរ៉ែវាស្ថិតនៅក្នុងដែនព្រៃសហគមន៍ដែលយើងចាត់ទុកថា វាស្ថិតចូលទៅក្នុងអាទិភាពទី១0របស់ Will Ads ហើយនិង Center Cardamoms ដូច្នេះសកម្មភាពស្រាវជ្រាង និងការធ្វើអាជីវកម្មលើរ៉ែ អ៊ីលម៉េនីត (Ilmenite) ក្នុងតំបន់នេះអាច នឹងនាំមកនូលប៉ះពាល់ពហុអវិជ្ជមាន បរិស្ថាន សង្គម និង សេដ្ឋកិច្ច ច្រើនយ៉ាងនៅក្នុងករណី ដែលម្ចាស់គំរោងមិនមានផែនការអាជីវកម្ម និងធ្វើផែនការ



Draft

គ្រប់គ្រងហេតុ ប៉ះពាល់បរិស្ថានឱ្យបានច្បាស់លាស់ទេ។ ដូច្នេះយើងបានចាត់ទុកថា គំរោងនេះជាគំរោងដែលមានផលប៉ះពាល់ នៅក្នុងចំណាត់ថ្នាក់ បី (Category B)។ គំរោងនេះស្ថិតនៅក្នុងកំរិតបរិស្ថាន B ឬក៏ C មូលហេតុអ្វី ដោយសារ ដើម្បីយើងធ្វើអាជីវកម្មរ៉ែ អ៊ីលម៉េនីត (Ilmenite) ទី១យើងនិយាយអំពីដំណើរការយករ៉ែ លាងរ៉ែ ហើយកែច្នៃរ៉ែ។ ប៉ុន្តែដើម្បីយើងធ្វើសង់រោងចក្រកែច្នៃរ៉ែ Ilmenite គឺវាត្រូវការចំណាយរុយច្រើន ដូច្នេះប្រទេសកម្ពុជានៅក្នុងពេលបច្ចុប្បន្នមិនអាចតម្លើងរោងចក្រចំរាញ់យករ៉ែ Ilmeniteទេ។ យើងជីកមកយើងគ្រាន់តែលាងដី ហើយយកថ្មដែលមិនមែនជា Ilmenite ចេញ និងរ៉ែនេះត្រូវបាននាំចេញទៅក្រៅប្រទេស បានន័យថាផលិតផលពាក់កណ្តាលសំរេច រ៉ែឆៅមិនមែនជារ៉ែសុទ្ធទេ។ យើងគ្រាន់តែជីកហើយលាងយករ៉ែដោយមិនដាក់គីមីអ្វីទេរបស់ក្រុមហ៊ុនសំណាងរ៉ែ។ ដូច្នេះហើយបានជាយើងឃើញការប៉ះពាល់ទៅលើធនធានបរិស្ថានគឺមានតិច។ ចំពោះ Ilmenite វាជាពាក្យមួយ ប៉ុន្តែបើសិនជាយើងប្រើនៅក្នុងភាសាគីមីវាជាទីប Titanium dioxide ជាវត្ថុធាតុដើមសំខាន់បំផុតនៅក្នុងឧស្សាហកម្មថ្នាំលាប វាជា Treatment មួយសំខាន់បំផុតនៅក្នុងការបញ្ចូលពណ៌ ធ្វើឱ្យពណ៌មិនហើរ ហើយជាប់បានយូរ។ ហេតុនេះហើយបានជាខ្ញុំចាត់ទុកថា វាជា Category B ព្រោះអីបរិមាណរ៉ែមានប្រហែលជា៤៥%ទេ ដូចនេះនៅពេលដែលយើងជីកយករ៉ែវាមានដុំថ្ម វាមានដី ពេលដំណើរការលាងយករ៉ែមិនបានរៀបចំប្រពន្ធ័រៀបចំលាងរ៉ែឱ្យបានត្រឹមត្រូវ វាអាចនាំយកជាតិកករ ធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់សហគមន៍នៅក្នុងតំបន់ខាងក្រោម ធ្វើទឹកកករ គុណភាពទឹកផ្លាស់ប្តូរ ហើយនៅតាម បាតព្រែក បាតអូរ ធ្វើឱ្យមានកដុះឡើង ធ្វើឱ្យកកស្ទះ។ ដូច្នេះហើយបានជាយើងថាក្រុមហ៊ុន បើមិនមានផែនការច្បាស់លាស់ទេវាអាចធ្វើឱ្យមានការប៉ះពាល់ដូចអ្វីដែលខ្ញុំបានលើកឡើង។ តទៅទៀតនេះ ខ្ញុំជំរាបជូនមួយៗថា តើវាមានការប៉ះពាល់យ៉ាងដូចម្តេចខ្លះ? ការប៉ះពាល់វាមាន១០ចំណុចសំខាន់ដែលមានដូចខាងក្រោម :

ចំណុចទី១ : ចំពោះការប្រើប្រាស់ដី យើងបែងជាពីរដំណាក់ការសំខាន់ទី(១) ការរំខានដល់ការប្រើប្រាស់នៅក្នុងដំណាក់ការស្រាវជ្រាវ និងរុករករ៉ែ ការរំខាន ទី(២)ការរំខាននៃការប្រើប្រាស់ដីនៅក្នុងដំណាក់ការធ្វើអាជីវកម្មរ៉ែ តើនៅក្នុងដំណាក់កាលទាំងពីរនោះវាប៉ះពាល់អ្វីខ្លះ។ ឧទាហរណ៍ថា នៅក្នុងដំណាក់កាលនៃការស្រាវជ្រាវ វាមានការឈូសឆាយផ្លូវចូលទៅក្នុងតំបន់ដែលសិក្សាស្រាវជ្រាវ វាមានសង់ផ្លូវ សង់ទីស្នាក់ការ សង់កន្លែងលាងរ៉ែ ទាំងអស់នេះវាទាមទាឱ្យយើងឈូសគំរបព្រៃចេញ វាធ្វើឱ្យមានការបែកដី ធ្វើឱ្យភ្លៀងអាចហូរនាំទៅ។ នៅតំបន់យើងនេះចាំបាច់ត្រូវយកចិត្តទុកដាក់ពីបញ្ហាហ្នឹង ដោយសារតែរដូវប្រាំងនៅតំបន់យើងនេះគឺមានតិចជាង៤ខែទេ ឥឡូវចុងខែហ្នឹងឬមួយដើមខែ១១ សឹងតែថារាំង ដូចជាខែ ១១ ខែ ១២ ខែ១ ចុងខែ១ឬមួយក៏ដើមខែ២ នៅក្នុងតំបន់យើងនេះចាប់ផ្តើមភ្លៀង។ ជាទូទៅកំពស់ទឹកភ្លៀងនៅតំបន់ហ្នឹងវាមានកំពស់ជាង ៣000ម.ម ក្នុងឆ្នាំ ហើយឆ្នាំខ្លះអាចរហូតទៅដល់ ៤0000ម.ម។ ដូចនេះខ្ញុំគិតថា Legislating ប្រចាំឆ្នាំខ្ពស់ អញ្ចឹងដំណើរការហូរច្រោះ និងការខូចខាតដីមានខ្ពស់។ ការហូរច្រោះទី១វាធ្វើឱ្យដីបាត់បង់

Draft

គុណភាព និងទី២នាំឱ្យមានដីកករល្អក់ Sediment ដីហើយវាជ្រាបតំបន់ទំនាប និងហូរទៅតាមអូរតាមព្រែកផ្សេងៗ។ ផលប៉ះពាល់បន្ទាប់មកទៀតពាក់ពន្ធ័ និងការបិទរណ្តៅរ៉ែ

ចំណុចទី ២:ចំពោះការបិទរណ្តៅរ៉ែ ប្រសិនបើក្រុមហ៊ុនមិនបានយកចិត្តទុកដាក់ក្នុងការបិទរណ្តៅរ៉ែទេ វាធ្វើឱ្យមានផលប៉ះពាល់ ទី១ពាក់ពន្ធ័ និងសោភណ័ភាព ទី២វាធ្វើឱ្យបាត់ទំលាប់សត្វព្រៃអាចធ្លាក់ទៅក្នុងរណ្តៅ ឡើងមកវិញមិនរួច។ បើយើងមិនបិទរណ្តៅហើយដាំឈើឡើងវិញវា និងបាត់បង់ គំរបព្រៃ

ចំណុចទី៣ និងទី៤: ការរំខាដោយសំឡេង និងការបំភាយឧស្ម័នផ្សេងៗ នៅកន្លែងនោះជាតំបន់ដាច់ស្រយាល ដូច្នេះសត្វព្រៃ សំឡេងពាក់ពន្ធ័ពីរ ប្រសិនបើគាត់អត់មានប្រពន្ធ័ការពារសុវត្ថិភាពដើម្បីបុគ្គលិកកម្មករច្បាស់លាស់ទេ វាអាចប៉ះពាល់ទៅដល់សុខភាព ហើយអាចឱ្យសត្វដែលវាធ្លាប់មករកស៊ីនៅក្នុងតំបន់និងវាអាចផ្លើលចេញទៅក្រៅ និងម្យ៉ាងទៀតការប្រើប្រាស់គ្រឿងចក្រសម្រាប់ជីកយករ៉ែ ហើយនិងគ្រឿងចក្រសំរាប់លាងរ៉ែ ដូច្នេះ វានឹងបញ្ចេញឧស្ម័នកាបូនិក និងសារធាតុបំពុលបរិយាកាសផ្សេងៗទៀតទៅក្នុងខ្យល់។

ចំណុចទី ៥ : ពាក់ពន្ធ័ទៅនឹងការបាត់បង់ទីជម្រក និងផលប៉ះពាល់លើសត្វព្រៃ ការបាត់បង់ជម្រកដូចឯកឧត្តម អស់លោកបានជ្រាបហើយថា រ៉ែអ៊ីលម៉េនីត វាខុសពីរ៉ែដទៃទៀតជាលក្ខណៈ Open Feet បានន័យថា យើង ចាំបាច់ត្រូវឈូសបើកគំរបព្រៃដើម្បីយករ៉ែតែម្តង យើងមិនបានខួងជាអណ្តូងរ៉ែហើយត្រូវទៅយករ៉ែនៅខាងក្រោមទេ អញ្ចឹងហើយបានបាត់បង់ទីជំរក។

ចំណុចទី ៦ :ពាក់ពន្ធ័ទៅនឹងតំបន់ការពារធម្មជាតិ ការបាត់បង់ទេសភាពធម្មជាតិ

ចំណុចទី ៧ : ហើយមួយទៀតពាក់ពន្ធ័នឹងអាកាសធាតុក្នុងដំណើរការ អាជីវកម្ម រយៈពេលនៃការធ្វើអាជីវកម្មសម្របមានរយៈពេលមិនវែង យើងមើលទៅភ្លៀង៣-៤ខែហើយ ដូច្នេះរយៈពេលដែលមិនសមស្របមានរហូតទៅដល់៨ខែ ប៉ុន្តែមិនមែនមានន័យថាក្រុមហ៊ុនមិនបានធ្វើអីនោះទេ ប្រសិនបើមានភ្លៀងធ្លាក់ខ្លាំង ៤-៥ថ្ងៃជាប់គ្នាក្រុមហ៊ុនមិនអាចធ្វើអ្វីបានទេ។

ចំណុចទី ៨ : ផលប៉ះពាល់ទៅលើសុខភាពការងារ និងផែនការ សុវត្ថិភាព និង ផលប៉ះពាល់លើសេដ្ឋកិច្ចជាតិ។

ចំណុចទី ៩-១០: ផលប៉ះពាល់ក្នុងតំបន់ និង ផលប៉ះពាល់បន្សំ ភាពចាំបាច់នៃការវាយតំលៃបន្ថែមនេះគឺជាផលប៉ះពាសល់សំខាន់ៗ ការធ្វើអាជីវកម្មអ៊ីលម៉េនីត។ ដូច្នេះយើងលើកមកទៀតថា តើយើងមានវិធានការណ៏សម្របសម្រួលអ្វីខ្លះដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងអស់នោះ។ ទី(១) ទាក់ទងទៅនឹងការរំខានចំពោះការប្រើប្រាស់ដី ការរំខានមិនអាចជៀសផុតទេ ខ្ញុំបានជំរាបជូនឯកឧត្តម អស់លោកជ្រាបស្រាប់ហើយថាវាពាក់ពន្ធ័នឹងការឈូសឆាយវាធ្វើឱ្យបាត់គំរបព្រៃ និងធ្វើឱ្យបែកដីមានការហូរច្រោះ ប្រសិនបើយើងមានវិធានការ ច្បាស់លាស់។ ឧទាហរណ៏ថា យើងឈូសដើមឈើនោះទៅ យើងកាត់វាកង់ៗហើយ ប្រមូលឈើទាំងអស់នោះ ទៅគរដាក់នៅលើទីទួលខ្ពស់ឱ្យផុតពីផ្លូវទឹក កំណាត់ឈើទាំងអស់នេះវាមិនបានហូរធ្លាក់ធ្វើរាំងស្ទះប្រពន្ធ័

ផ្លូវទឹកទាំងអស់នោះទេ។ នេះជាវិធានការកាត់បន្ថយចំពោះការប្រើប្រាស់ដី ហើយបើមានភ្លៀងធ្លាក់ក៏មិនអាចដំណើរការឈូសឆាយបានដែរ ព្រោះអីនៅពេលដែលកំពុងឈូសឆាយដីវាបែកភ្លៀងធ្លាក់ខ្លាំងមកធ្វើឱ្យហូរដីនោះអស់ហូរចូលទៅក្នុងប្រពន្ធ័អូរព្រែក។ ទី(២) មិនត្រូវដំណើរការអាជីវកម្មរ៉ែនៅពេលមានភ្លៀងធ្លាក់ទេ។ ការបិទរណ្ដៅរ៉ែ និងការដាំដើមឈើឡើងវិញ ធម្មតាជាទូទៅពាក់ពន្ធ័ និងបញ្ហានេះក្រុមហ៊ុនត្រូវតែដឹងថាមួយឆ្នាំតើក្រុមហ៊ុនត្រូវការជីករ៉ែបានប៉ុន្មាន ហើយលទ្ធភាពក្រុមហ៊ុន១ខែយកស្រែបាន ៣០០០តោន ក្នុង១ឆ្នាំក្រុមហ៊ុនមានលទ្ធភាពយករ៉ែតែ ៣៦០០០តោនទេ។ ដូច្នេះយើងមើលទៅលើបរិមាណរ៉ែសរុបវិញ ចំនួន ២៤០០០០០តោន គាត់ត្រូវយករយៈពេល១០០ឆ្នាំ បើយើងគិតត្រួស១ថាទំហំដីជាង៧០០០ហិកតា នៅក្នុងរយៈពេលនៃការធ្វើអាជីវកម្មរ៉ែ១០០០ឆ្នាំ មួយឆ្នាំគាត់ត្រូវប្រើប្រាស់ដីអស់តែ៧០ហិកតា តែប៉ុណ្ណោះ។ យើងត្រូវបំបែកទៀតតួលេខ ៧០ហិកតា តើក្នុង៧០ហិកតា ដែលមានបរិមាណរ៉ែ ៣៦០០០តោន ក្នុង១ឆ្នាំវាមានកំណរ៉ែតែវាមិនមានជាតិគីមីទេតែវាជាអាចម៍ដីនិងបំណែកថ្មដែលគ្មានរ៉ែអ៊ីលម៉េនីតនៅក្នុងនោះ។ ដូច្នេះក្រុមហ៊ុនសំណាងរ៉ែត្បូងថ្មចាំបាច់ត្រូវថា គណនាបរិមាណអាចម៍រ៉ែសរុបចំនួនប៉ុន្មាន នៅពេលក្រោយពេលដែលយករ៉ែអស់ បាន៣៦០០០តោន ហើយអាចម៍រ៉ែនោះប្រើដើម្បីលប់រណ្ដៅ ប៉ុន្តែដោយសារថាយើងបានដកយករ៉ែ ៣៦០០០តោន ហើយចំណុចមួយទៀតដែលយើងត្រូវសួរថា រណ្ដៅទំហំប៉ុន្មាដែលក្រុមហ៊ុនមិនអាចលប់។ ប្រសិនបើយើងយកបរិមាណរ៉ែ៣៦០០០តោន យកទៅដាក់ក្នុងរណ្ដៅមួទៀតទំហំនឹងមិនអាចដល់កន្លះហិកតាទេដោយសារដង់ស៊ីរបស់រ៉ែខ្ពស់ បើរ៉ែទំហំ១ម៉ែត្រគូប ដូច្នេះ៣៦០០០ហិកតា ស្មើនឹងទំហំផ្ទៃដី១ហិកតា ហើយជំរៅ៣.៥ម តែប៉ុណ្ណឹងទេ។ ប៉ុន្តែដោយសារថាក្រុមហ៊ុនរ៉ែ អ៊ីលម៉េនីត ជាប្រភេទគីមីមេតាល់ធ្ងន់បានន័យថាយើងឈូសអាចម៍រ៉ែលប់រណ្ដៅនោះវិញ រណ្ដៅដែលនៅសល់នោះគឺមានទំហំតូច។ ហើយសំខាន់បំផុតថ្នាក់ដឹកនាំមូលដ្ឋានតាមខេត្តស្រុកភូមិ និងស្ថាប័នពាក់នៅភ្នំពេញនោះត្រូវតាមដានពិនិត្យវាយតំលៃថា តើក្រុមហ៊ុនសំណាងរ៉ែ ត្បូងថ្មនេះអនុវត្តន៏ទៅតាមផែនការអាជីវកម្មរ៉ែ និងយកចិត្តទុកដាក់ចំពោះបរិស្ថានយ៉ាងដូចម្ដេច។ នៅពេលចប់ ឆ្នាំទី១គាត់ត្រូវតែលប់រណ្ដៅរ៉ែហ្នឹង ហើយត្រូវដាំឈើឡើងវិញ បន្ទាប់មកគាត់អាចទៅធ្វើកន្លែងទី២បាន។

ចំណែកឯសំឡេង និងការបំភាយក្រៅពីបុគ្គលិកប្រហែលជា២០០នាក់នៅតំបន់នឹង នៅពេលដំណើរការអាជីវកម្មពេញលេញគឺមិនមានអ្នកណាទៅទេពីព្រោះវាជាតំបន់ដាច់ស្រយាល។ នៅកន្លែងអាជីវកម្មរ៉ែដែលវាមានសំឡេងខ្លាំង បុគ្គលិកកម្មករទាំងអស់អាចពាក់ឧបករណ៏ការពារត្រចៀកសំលេងអាចកាត់បន្ថយបាន ហើយការកត់បន្ថយឧស្មន័កាបូនិកនៅក្នុងតំបន់គឺយើងមិនអាចកាត់បន្ថយបានទេ វាមានប៉ុន្មានគឺវាបញ្ចេញទៅប៉ុណ្ណឹងហើយ ប៉ុន្តែដោយសារថា តំបន់ជុំវិញវាសំបូរទៅដោយធនធានធម្មជាតិ យើងមានការជឿជាក់ថា ឧស្មន័កាបូនិកត្រូវបានស្រូបយកដោយរុក្ខជាតិបៃតងទាំងអស់។ ចំពោះការបាត់បង់ទីជំរក ហើយនិងផលប៉ះពាល់លើសត្វព្រៃ បញ្ហានេះក៏ជាផលប៉ះពាល់ដែលជៀសមិនរួចដែរ ប៉ុន្តែដូចឯកឧត្តមអស់លោកបាន

Draft

ជ្រាបស្រាប់ នៅក្នុងមួយឆ្នាំបើគាត់ធ្វើអាជីវកម្មរ៉ែពេញលេញ ផ្ទៃព្រៃដែលគាត់ឈូសចេញគឺមានតែទំហំ ៧០ហិកតាទេ។ ដូចនេះយើងចាត់ទុកថាជាប្រភេតនៃផលប៉ពាល់បណ្តោះអាសន្នរយៈពេលមធ្យម។ នៅឆ្នាំបន្ទប់មកទៀតគាត់លុបហើយគាត់ដាំព្រៃឡើងវិញ ខ្ញុំគិតថានៅក្នុងរយៈពេល៧-៨ឆ្នាំក្រោយព្រៃនឹងអាចដុស ៨-១០មឡើងវិញហើយ។ ចំណែកឯផលប៉ះពាល់លើសត្វព្រៃក៏ជាផលប៉ះពាល់បន្ទាប់បន្សំប៉ុន្តែ យើងគិតថានៅជុំវិញផ្ទៃដីអាជីវកម្មរ៉ែនោះសុទ្ធតែជាតំបន់ការពារទាំងអស់។ នៅពេលវត្តមានរបស់មនុស្ស និងសំឡេងអ្វីផ្សេងៗ សត្វព្រៃទាំងអស់នោះអាចផ្អើល ប៉ុន្តែគាត់ធ្វើបំលាស់ទីចេញទៅតំបន់ឆ្ងាយទៅ ហើយពេលណាមួយដែលយើងបិទរណ្តៅរ៉ែជាស្ថាពរសត្វព្រៃទាំងអស់អាចត្រឡប់មកវិញបាន នេះគឺផ្នែកមួយផ្នែកមួយទៀតការប៉ះពាល់ទៅលើសត្វធម្មតាមានវត្តរបស់មនុស្សទៅដល់កន្លែងណា វាធ្វើឱ្យកើនសម្ពាធចំពោះសត្វព្រៃ ដោយសារកម្មករ បុគ្គលិក ឬមួយសន្តិសុខអាចទៅធ្វើការបរបាញ់សត្វព្រៃ តែបើក្រុមហ៊ុនគាត់មានវិធានការណ៍ច្បាស់លាស់ គាត់អាចធ្វើបំរាម ការកំណត់ធ្វីបទបញ្ជាផ្ទៃក្នុង រាល់បុគ្គលិក កម្មករទាំងអត់មានអ្នកណាមានសិទ្ធធ្វើការបរបាញ់សត្វ នៅតំបន់នោះបាន អញ្ចឹងយើងអាចទប់ស្កាត់បានហើយ។ បន្ទាប់មកទៀតយើងមើលទៅលើផលប៉ះពាល់ធម្មជាតិចំណុចនេះសឹងតែថាអត់មាន ពីព្រោះអីតំបន់នោះជាតំបន់មួយបិទជិតវាឆាយអំពីក្រសែភ្នែករបស់អ្នកដំទៃ ហើយដោយសារថានៅពេលដែលយើងជីករ៉ែទាំងអាចម៍យកទៅតំបន់ដទៃទៀតធ្វើឱ្យនៅសល់រណ្តៅរ៉ែរាប់ពាន់ ហិកតា គឺវាមិនមានទេ ក្រោយពេលដែលបិទហើយយើងដាំព្រៃឡើងវិញ។ ដូច្នេះកន្លែងនោះគឺអត់មានរណ្តៅរ៉ែទេ។ ចំពោះការបាត់បង់ទៅលើតំបន់ការពារ និងតំបន់ទេសភាពធម្មជាតិក៏យើងអាចកាត់បន្ថយបានដែរ។ ចំណុចបន្ទាប់មទៀតផលប៉ះពាល់របស់អាកាសធាតុទៅលើ ប្រតិបត្តិការអាជីវកម្មរ៉ែមិនចាំបាច់បកស្រាយជូនឯកឧត្តម អស់លោកទេ ពីព្រោះនេះជាបញ្ហារបស់ក្រុមហ៊ុន ខ្ញុំគិតថាក្រុមហ៊ុនចេះសម្របសម្រួលធ្វើយ៉ាងណា អ្វីដែលជាដំណោះស្រាយរបស់គាត់នៅក្នុងរដូវសមស្របគាត់អាចបង្កើនពេលវេលាធ្វើអាជីវកម្មចំណែកឯនៅក្នុងរដូវមិនសមស្របគាត់អាចឈប់នៅពេលដែលមានភ្លៀងខ្លាំង ដូចនេះវាអាចធ្វើឱ្យមានតុល្យភាពចំណូល និងចំណាយនៅក្នុងក្រុមហ៊ុនគាត់បាន។ ហើយផលប៉ះពាល់ទៅលើសុខភាពវាកើតមាន ប៉ុន្តែ ខ្ញុំក៏មិនចាំបាច់លើកយកមកដែរ នេះគឺចាំទៅដល់ប្រជុំថ្នាក់ក្រសួង នៅពេលនោះខ្ញុំអាចលើកបញ្ហាសុខភាពមកបកស្រាយឱ្យបានច្បាស់លាស់។ ហើយផលប៉ះពាល់នៅក្នុងតំបន់គិតថា ចំពោះមុខមិនអាចធ្វើការបកស្រាយលំអិតបាន ពីព្រោះថា ក្រៅអំពីក្រុមហ៊ុន សំណាងរ៉ែ ត្បូងថ្មដែលមានផ្ទៃដីជាង៧០០០ហិកតាហើយរយៈពេលនៃការធ្វើអាជីវកម្ម១០០ឆ្នាំ ខ្ញុំមិនទាន់ដឹងថានៅតំបន់ក្បែរនឹងតើមានគំរោងធ្វើអាជីវកម្មរ៉ែយ៉ាងណានោះទេ។ ដូច្នេះផលប៉ះពាល់នៅក្នុងតំបន់យើងមិនអាចបកស្រាយជូនបានទេ។ នៅក្នុងផលប៉ះពាល់ក្នុងតំបន់ និងផលប៉ះពាល់បន្សំគឺវាមានលក្ខណៈរួមគ្នា។ ផលប៉ះពាល់បន្សំ ឧទាហរណ៍ថា ឥឡូវយើងជីករ៉ែនៅកន្លែងនឹងហើយ វាមានផលប៉ះពាល់តិចមួយ ប៉ុន្តែចេញពីនេះ១០គ.មស្រាប់តែមានរណ្តៅរ៉ែមួយទៀត ហើយជាប់ៗគ្នាអាចមានរណ្តៅរ៉ែ បួនដប់ម្តៃ រួមគ្នា។ ដូច្នេះផលប៉ះពាល់វាតិចពីគំរោងមួយទៅគំរោងមួយ បើគំរោង



Draft

ច្រើនវាធ្វើឱ្យផលប៉ះពាល់ធំ ។ បច្ចុប្បន្នទើបតែមានរ៉ែអ៊ីលម៉េនីតមួយនៅក្នុងតំបន់ ហើយផលប៉ះពាល់ខន្សំនៅកន្លែងនឹងយើងក៏មិនអាចបកស្រាយបានដែរ ។

ចំណុចបន្ទាប់មកទៀតនេះជាចំណុចសំខាន់ដែលខ្ញុំត្រូវតែយកមកលើក ដោយសារតែក្រុមហ៊ុនសំណាងរ៉ែត្បូងថ្ម មិនទាន់បានដំណើរការអាជីវកម្ម ដូច្នេះយើងមិនទាន់វាយតំលៃបានជាក់លាក់ថា តើវានឹងមានផលប៉ះពាល់អ្វីផ្សេងទៀត។ ដូច្នេះយើងចាំបាច់បង្កើតចំណុចមួយទៀត ដែលហៅថា Additional Impact Assent Requirements ហើយអ្វីទៅ ដែលយើងចាំបាច់ត្រូវធ្វើការវាយតំលៃបន្ថែមក្រោយពេលដែលក្រុមហ៊ុន សំណាងរ៉ែ ត្បូងថ្មដំណើរការអាជីវកម្មនោះ យើងទៅលើលក្ខណៈគីមី ពេលដែលគាត់ដំណើរបាន៣ខែ យើងមើលគំនរអាចម៍រ៉ែគាត់ ធម្មតាមិនមែនទាល់តែយើងយកធាតុគីមីយកទៅដាក់បានធ្វើឱ្យប៉ះពាល់ទេ នៅក្នុងធម្មជាតិក៏មានគីមីដែរ ក៏ប៉ុន្តែគីមីនឹងគឺវា Higden វាអាចិកំបាំងមិនបង្ហាញតែម្តងទាល់តែមានការជីកកាយដីនៅក្នុងបរិមាណច្រើនបានជាតិគីមីវាបញ្ចេញមក។ នៅក្នុងវិធានការណ៍បរិស្ថានរបស់យើង១ នឹងដាក់ថាក្រោយពេលដែលក្រុមហ៊ុន ដំណើរការអាជីវកម្ម ហើយអាចរ៉ែមានលើសពី ៥០០០ម$^{៣}$ ត្រូវមានគណៈកម្មការអន្តរក្រសួងមួយដែលមានសហសភាពបច្ចេកទេសចាំបាច់ត្រូវចុះទៅពិនិត្យអាចម៍រ៉ែនោះ។ ដូច្នេះចំណុចទាំងបីចុងក្រោយនេះយើងធ្វើការបកស្រាយ ជាជំហាន១ ពីព្រោះនៅក្រសួងបិរស្ថាន មានក្រុមការងារមួយពាក់ពន្ធ័ E&M បានន័យថា Evaluation Monitoring Programe កម្មវិធីតាមដានត្រួតពិនិត្យ និងវាយតំលៃ ទុកឱ្យក្រុមហ៊ុនដំណើរការអាជីវកម្មសិន ហើយ៣ខែក្រោយនៅពេលដែលបរិមាណអាចរ៉ែមានលើសពី ៥០០០ម$^{៣}$ ចាំបាច់ត្រូវចុះត្រួតពិនិត្យ ហើយយើងនិងលើកយកបញ្ហានេះទៅពិភាក្សានៅជំហានក្រោយទៀត ខ្ញុំសូមបញ្ចប់ការអត្ថាធិប្បាយតែត្រឹមនេះ ទុកឱកាសឱ្យថ្នាក់ដឹកនាំខេត្ត និងអស់លោកជាប្រធានមន្ទីរពាក់ពន្ធ័ទាំងអស់លើជាបញ្ហាផ្សេង១មក ខ្ញុំ នឹងធ្វើការបំភ្លឺជូនបន្ថែមទៀត។

Draft

**ឯកឧត្តម សុន តារា** អភិបាលរង ខេត្តកោះកុងៈ សូមអរគុណដល់ **បណ្ឌិត លី សុពណ៌ មុនី** ដែលបានធ្វើបង្ហាញពីហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុនស្វែងរក និងរុករករ៉ែ អ៊ីលម៉េនីត ហើយអ្វីដែលពាក់ពន្ធ័ និងបុព្វហេតុច្បាប់នៅក្នុងរបាយការណ៍នេះ ដើម្បីអង្គភាពពាក់ពន្ធ័ផ្តល់យោបល់បន្ថែមនោះ សុំឱ្យខាងមន្ទីរ ឧស្សាហកម្មដែលជាមន្ទីរជំនាញផ្ទាល់នោះ តើពាក់ពន្ធ័និងទីតាំងនោះមានលិខិតអនុញ្ញាតិ ក្នុងការស្វែងរកជំរករ៉ែ និងរុករករ៉ែដើម្បីដាក់ជូនអង្គពិភាក្សាថ្ងៃនេះបានស្តាប់ បន្ទាប់មកទេ្តខាងព្រៃឈើ ។

**លោក ម៉ិច ស៊ីយុន ប្រធានមន្ទីរឧស្សាហកម្ម :** សូមគោពឯកឧត្តមអភិបាលរងខេត្ត លោកបណ្ឌិតលី សុពណ៌-មុនី ដែលបានធ្វើបទបង្ហាញអម្បាញ់មិញ ពាក់ពន្ធ័ទៅនឹងជំនាញចូលរួមថ្ងៃនេះ ដើម្បីការពារ ដែលស្ថាបន័និមួយ១ទទួលខុសត្រូវ ។ ពាក់ពន្ធ័ទៅលើច្បាប់អាជីវកម្ម ដែលបានស្នើសុំពីក្រសួងឧស្សាហកម្ម ដើម្បី

ធ្វើការសិក្សាស្រាវជ្រាវ កន្លងមកនេះមានពិតមែនហើយក្រសួងឧស្សាហកម្មបានចេញឱ្យដើម្បីដំណើរការអាជីវកម្ម ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា រយៈកាលកន្លងមកសកម្មភាពរបស់ក្រុមហ៊ុននេះ គឺមានការខ្វះចន្លោះ ពាក់ពន្ធ័នឹងអាជ្ញធរមូលដ្ឋានក៏ដូចជាខាងមន្ទីរជំនាញ ហើយរាល់របាយការណ៍ និងការងារផ្សេងៗក្រុមហ៊ុនមិនដែលទំនាក់ទំនងអ្វីទាំងអស់។ ហើយការណ៍អ្វីៗគេបញ្ជូនទៅក្រសួង ពេលខ្លះក៏អត់ទៅដល់ក្រសួងទៀត បច្ចុប្បន្ននេះឈានទៅដល់ការតមួយទៀត ការសុំធ្វើបុកធ្វើអាជីវកម្មរ៉ែបន្តទៅទៀត។ ដូច្នេះនៅពេលដែលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្មពីក្រសួងឧស្សាហកម្ម ស្នើសុំកុំឱ្យធ្វើដូចមុនទៀត។ ហើយនេះជាដំណាក់កាលមួយសំខាន់ណាស់ ទី(១)ការត្រួតពិនិត្យរាល់ផែនការផ្សេងៗដែលក្រុមហ៊ុនបានធ្វើ និងអនុវត្តរាល់ឆ្នាំ គឺត្រូវធ្វើរបាយការណ៍ឱ្យបានច្បាស់លាស់បញ្ជាក់អំពីបរិមាណដែលធ្វើបាន និងសកម្មភាពផ្សេងៗទៀត។ ក្នុងករណីនេះដើម្បីឱ្យការធ្វើអាជីវកម្មវាមានផលប្រយោជន៏សំរាប់ជាតិ កុំធ្វើផ្សេងពីនេះគឺធ្វើអ្វីទៅតាមតែផែនការរបស់ខ្លួន បើថាយករ៉ែប្រាកដជាយករ៉ែ កុំធ្វើអ្វីផ្សេងទៀត។ ដើម្បីឱ្យងាយស្រួល មន្ទីរបានស្នើសុំបញ្ចូលមន្ត្រីមន្ទីរឧស្សាកម្មរ៉ែ និងថាមពល ដើម្បីឈរជើងនៅលើការដ្ឋាននោះចំនួន២នាក់ ហើយនេះក៏មិនមែនជារឿងថ្មីទេ ព្រោះថានៅកន្លែងផ្សេងៗទៀតក៏គេបញ្ជូនមន្ត្រីប្រចាំការដូចអញ្ចឹងដែរ នេះមិនមែនដើម្បីអ្វីទេ គឺដើម្បីសម្របសម្រួលការងាររវាងក្រុមហ៊ុនជាមួយស្ថាប័នរដ្ឋដើម្បីស៊ីសង្វាក់គ្នានៅពេលដែលយើងអនុវត្តការងារ។ ម្យ៉ាងទៀត Rrport បញ្ជូនទៅក្រសួង ហើយ Report មន្ទីរស្ថាបន័ក៏បញ្ជូនទៅក្រសួង ដូច្នេះ Report ទាំងពីរនឹងត្រូវស៊ីគ្នាដែរ។ ដូច្នេះហើយបានជាខ្ញុំគិតឃើញត្រូវបញ្ជូនមន្ត្រីពីរនាក់នៅពេលដែលក្រុមហ៊ុននឹងបានទទួលនូវអាជ្ញាប័ណ្ណអាជីវកម្មរ៉ែនេះ។ ជាបន្តទៅទៀត ខ្ញុំសូមសួរចំពោះទំហំ និងបរិមាណរ៉ែដែលមាននៅតំបន់ដែលមានចំនួន១០ស្រទាប់ ហើយការធ្វើអាជីវកម្មទៅច្រើនឆ្នាំ គឺ១០០ឆ្នាំ ហើយបរិមាណរ៉ែមានរហូតដល់ទៅ ២៤០០០០០តោន តើក្រុមហ៊ុនមានកាតព្វកិច្ចក្នុងការបំពេញរណ្តៅដីនោះឡើងវិញ? នេះចំពោះតែអ៊ីលម៉េនីតចំពោះសមាសភាពផ្សេងទៀតក្រៅពីអ៊ីលម៉េនីត ដែលវាមានប្រយោជន៏សក្តានុពលរបស់ជាតិផ្សេងទៀតត្រូវធ្វើរបាយការជូនមន្ទីរ និងក្រសួងឱ្យបានដឹងជាមុនៗនិងធ្វើអាជីវកម្ម។

**លោក មាស ស៊ីថា នាយរងខណ្ឌរដ្ឋបាលព្រៃឈើខេត្ត :** សូមគោរពឯកឧត្តមអភិបាលរងខេត្ត និងលោកតំណាងឱ្យក្រុមការងារវាយតំលៃ ក្នុងនាមខ្ញុំតំណាងឱ្យរដ្ឋបាលព្រៃឈើខេត្តកោះកុង បើតាមខ្ញុំក្តាប់ការអធិប្បាយរបស់គាត់ គឺថាមានផលប៉ះពាល់ច្រើនចំពោះតំបន់យករ៉ែនេះ ហើយតំបន់យករ៉ែស្ថិតក្នុងអនុក្រឹត្យលេខ ៦៥ របស់រាជរដ្ឋាភិបាលដែលប្រគល់ឱ្យ Wile Aids ជាអ្នកគ្រប់គ្រង ក្នុងរយៈកន្លងមកនេះមិនមាននរណាធ្វើអ្វីបានទេនៅម្តុំនឹង ហើយដែលក្រុមហ៊ុនធ្វើអ្វីៗនោះខាងខ្ញុំក៏អត់ដឹងដូចមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តដែរ ទើបតែបានដឹងថ្ងៃនេះ។ ខ្ញុំមានការព្រួយបារម្ភមែនទែនគឺបើកការដ្ឋានហើយធ្វើផ្លូវចូលទៅដល់ការដ្ឋាន តើក្រុមហ៊ុនមានវិធានការអ្វីចំពោះការធ្វើផ្លូវនេះ ហើយមានទំហំប៉ុណ្ណា។ កាលធ្វើផ្លូវចូលទៅប្រជាជនត្រូវទៅចាប់ដីតាមផ្លូវនឹងហើយ តើក្រុមហ៊ុនមានវិធានការអ្វីចំពោះប្រជាជន ក្រៅពីកម្មករ ការ

Draft

ដ្ឋានចូលទៅក្នុងនោះ? តើក្រុមហ៊ុនមានវិធានការយ៉ាងណា (ព្រោះឈើនោះជាឈើសំណល់) ពេលដែលក្រុមហ៊ុនៈ កាប់ឈើយកទៅណា ឬមួយទិញពីរដ្ឋ ឬមួយក្រុមហ៊ុនលក់ឱ្យអ្នកផ្សេង។ កន្លងមកយើងឃើញក្រុមហ៊ុន អគ្គិសនីគាត់កាប់ហើយគាត់ចោលអារត់អារាយ ដល់រដ្ឋបាលព្រៃឈើទៅមើលគាត់ថាគាត់ទិញចង់លុយជូនរដ្ឋ តែដល់គាត់ កុនមែនទែន គាត់ឈូសលុបតែម្តង ប្រាប់គាត់ថាឱ្យគរម៉ុ បើគាត់មិនយករដ្ឋមានវិធានការលក់ឱ្យ ក្រុមហ៊ុនណាមួយដែលគេចង់បានឈើនឹង ប៉ុន្តែគាត់ឈូសចោល ផលប៉ះពាល់វាមានច្រើនអញ្ចឹង តើក្រុមហ៊ុនមាន វិធានការយ៉ាងដូចម្តេច ឈើកាប់ហើយជាឈើសំណល់ ឈើប្រើបានទុកគររបៀបដូចម្តេច? ហើយក្នុងការដាំ ឈើគួរឱ្យរដ្ឋបាលព្រៃឈើចូលទៅមើល។ ការកាប់ឈើនោះរបៀបយ៉ាងដូចម្តេច បើក្រុមហ៊ុននោះបង់យកថ្លៃ យកឈើនឹងក៏យក បើក្រុមហ៊ុនមិនមានលទ្ធភាពយកឈើនឹងទេ ឬលក់ក្រុមហ៊ុនអាជីវកម្មណាដែលគេចង់បាន ទិញពីនោះវិញ។

ផលប៉ះពាល់មួយទៀតគឺថា គាត់និយាយម្យ៉ាងដែលហើយទទួលស្គាល់ថាធ្វើយ៉ាងនេះ យ៉ាងនោះទុក ដីដាំអ្វីវិញនោះ ប៉ុន្តែរយៈកន្លងមកក្រុមហ៊ុនធ្វើអាជីវកម្មឈើមានផែនការដូចគ្នាអញ្ចឹងដល់ពេលធ្វើអត់មានដាំ។ ការដាំឈើនោះក្រុមហ៊ុនដាំខ្លួនឯង ឬមួយប្រគល់លុយទៅឱ្យរដ្ឋឬមួយអ្នកណាទៅដាំ កន្លងមកក្រុមហ៊ុនកាប់ ឈើគាត់ប្រគល់លុយទៅឱ្យក្រសួងហិរញ្ញវត្ថុទំហាក់លុយមកឱ្យក្រសួងកសិកម្មដាំ ការដាំមិនសូវមានលទ្ធផល ប៉ុន្មានទេតាមតែខ្ញុំដឹង។

**បណ្ឌិត លី សុពណ៌ មុនី** : ខ្ញុំសូមអរគុណចំណុចនេះ សូមការអនុញ្ញាតពីឯកឧត្តម ដើម្បីបំភ្លឺ ជូនទៅ និងសំណួរពីរខាងដើមជាការពិតសេចក្តីបារម្ភរបស់យើង កន្លែងណាក៏ដោយ ដែលមានគំរោង អភិវឌ្ឍន៍ មានការសង់ផ្លូវចូលហៅថា Action Road វាតែងតែធ្វើឱ្យមានសម្ពាធទៅលើការប្រើប្រាស់ដី នៅប្រទេសដទៃយ៉ាងណានោះខ្ញុំមិនដឹង ក៏ប៉ុន្តែប្រទេសយើងគ្រប់កន្លែង១ណាឱ្យតែមានការអភិវឌ្ឍន៍ ដូច ឯកឧត្តមជ្រាបស្រាប់ហើយដីយើងនៅស្រែអំបិលមុនពេលឧកញ្ញា **លី យ៉ុងផាត់** គាត់មកអភិវឌ្ឍន៍នៅ កន្លែងនឹងអត់មានអ្នកណាចាប់អារម្មណ៍ទេ ប៉ុន្តែឱ្យតែឮអ្នកវិនិយោគទៅដល់កន្លែងណាហើយ មនុស្សមិន ដឹងមកពីកន្លែងណាទេទៅចាប់បង្គជាបញ្ហាទេ ឱ្យអាជ្ញាធរមូលដ្ឋានហើយបង្កការរាំងស្ទះជាឧបសគ្គដល់ទៅ អ្នកវិនិយោគិននឹងថែមទៀត។ ហើយខ្ញុំគ្រាន់តែថាទៅលើបញ្ហាទី១ក្តី ទៅលើបញ្ហាទី២ក្តី មិនមែនជារឿង របស់ក្រុមហ៊ុនទេ មកពីក្រុមហ៊ុនគ្នានៅឯកជន ចង់មិនចង់គាត់ធ្វើយ៉ាងម៉េចឱ្យផលចំណេញរបស់គាត់កើន ឡើង អ្វីដែលជាអាជ្ញាធរមូលដ្ឋាន ហើយនិងស្ថាប័នពាក់ពន្ធ័នៅភ្នំពេញឯណោះទេជាអ្នកពិនិត្យតាមដាន ហើយវាយតំលៃ យើងមានច្បាប់ប្រសិនបើធ្វើខុស ១ម្តង ២ដង ៣ដង ទៅតាមការណែនាំ បើគាត់អត់ អនុវត្ត ជាពិសេសខេត្តស្នើរឡើងទៅលើយើងត្រូវមានសិទ្ធដកហូតតែម្តង។ ដូច្នេះ ខ្ញុំគិតថាសំណួរនេះគួរ យើងពិភាក្សានៅ ក្នុងក៏រិតស្ថាប័នវិញ តើយើងពង្រឹងច្បាប់យើង ហើយយើងធ្វើឱ្យដៃគូឯកជនរបស់យើង មានការចូលរួម យ៉ាងម៉េចខ្លះនៅក្នុងការអនុវត្តន៏របស់គាត់ គំរោងភាគច្រើន ខ្ញុំគិតថាមិនមែនតែអ៊ីល

ម៉ែនីតមួយទេ ខ្ញុំសិក្សាគំរោងច្រើនពាក់ពន្ធ័ និង EIA ក៏ប៉ុន្តែវិធានការសំខាន់វិធានការកាត់បន្ថយផលប៉ះពាល់ទាំងបរិស្ថាន ទាំងសង្គម ទាំងអស់នឹងមិនត្រូវបានយកទៅអនុវត្តឱ្យមានប្រសិទ្ធភាព ក្រុមហ៊ុនចាំតែអនុវត្តទេ ទោះបីគាត់មិនចង់ក្តី បើយើងថាលោកឯងត្រូវតែលប់ដីឡើងវិញ លោកឯងត្រូវតែដាំឈើឡើងវិញ ក្រោយពេលឈូសហើយឈើគរទុកឱ្យមានសណ្តាប់ធ្នាប់ ឬមួយក៏ដាក់ឱ្យមានការដេញថ្លៃ ទោះបីជាទៅជាឈើអុសក្តី ឬមួយជីវម៉ាស់ក្តី សុទ្ធតែមាននិតិវិធីទាំងអស់។ ប៉ុន្តែសំខាន់ដំណើរការអនុវត្តឱ្យមានប្រសិទ្ធភាព ហើយខ្ញុំគិតថាមិនមែនក្រុមហ៊ុនអនុវត្តខ្លួនឯង មិនមានការតាមដានវាយតំលៃ ហើយតំរូវឱ្យក្រុមហ៊ុនទទួលខុសត្រូវលើបញ្ហានឹងពិតជាពិបាកហើយ។

**លោក ង៉ែ ពេជរតនា ប្រធានមន្ទីរបរិស្ថាន** ៖ ខ្ញុំបានតាមដាននូវការធ្វើបទបង្ហាញអំពីការស្រាវជ្រាវរ៉ែនេះ ឃើញថាមានការប៉ះពាល់សំខាន់នៅតំបន់នោះ គឺពាក់ពន្ធ័ទី១ សង្គមនិងសេដ្ឋកិច្ចដូចលោកបណ្ឌិត **លី សុពណ៌-មុនី** បានបង្ហាញហើយ វាមិនសូវប៉ះពាល់ប៉ុន្មានទេ តែវាពាក់ពន្ធ័ទៅលើបរិស្ថានធម្មជាតិហើយដែលជាសំខាន់បំផុតនោះ ព្រៃឈើ សត្វព្រៃ និងជលផល(ក្តោបទាំងអស់លើមច្ឆាជាតិ ទាំងអណ្តើក និងក្រពើ)រួមមានទាំងដែលរស់នៅក្នុងទឹក។ ដូច្នេះ ខ្ញុំគិតថា នៅពេលដែលគំរោងដំណើរការ ដែលមានក្នុងផែនការរបស់គាត់ ១ខែ ក្រុមហ៊ុនអាចមានលទ្ធភាពយករ៉ែរហូតដល់ទៅ៣០០០តោន ហើយគ្របដណ្តប់នៅលើផ្ទៃដី៧០ហិកតា ១ឆ្នាំម្តង នៅពេលប្រតិបត្តិការនេះអ្វីដែលខ្ញុំព្រួយបារម្ភគឺ ព្រៃឈើនេះដែលលោកខាងមេព្រៃបានលើកហើយ បើកាលណាយករ៉ែៗនៅក្រោមដីឯណោះ ដូច្នេះត្រូវសំអាតព្រៃឈើ តើព្រៃឈើត្រូវយ៉ាងដូចម្តេច? ជាគំនិតខ្ញុំ ដែលយើងធ្លាប់ធ្វើកន្លងមកដែរ ឈើត្រូវតែដេញថ្លៃលក់មុន និងការជីកយករ៉ែ ក្រុមហ៊ុនត្រូវប្រកាសឬរដ្ឋត្រូវប្រកាសដេញថ្លៃលក់ដើម្បីសំអាតព្រៃឱ្យអស់ហើយចាំចាប់ផ្តើមជីកយករ៉ែ៧០ហិកតា ឬប៉ុន្មានហិកតាទៅតាមទំហំរបស់រ៉ែនោះ។ ចំពោះដំណើរការយករ៉ែនឹងយើងត្រូវលាងហើយកទេចកំទីរ៉ែនេះដែលជាបញ្ហាធ្ងន់វាហូរមកប្រពន្ធ័ព្រែកទាំងឡាយមកតំបន់ផ្នែកខាងក្រោមនេះ ដូចជាព្រែកត្រពាំងរូង ព្រែកតាតៃ ធ្វើឱ្យប៉ះពាល់ និងបាត់បង់ជំរកត្រី ហើយជាពិសេសជីវចំរុះតូចៗ។ យើងមិនដឹងថានៅតំបន់មានសត្វពិសេសអ្វីទេកន្លងមកបើតាមអង្គការ Wall ADDs ឬអង្គការ ជី មានតាំងពីក្រពើភ្នំ ត្រីនាគ កាលណាយើងធ្វើអាជីវកម្មរ៉ែនេះទៅ ទី១បាត់បង់ជំរកវាតែម្តង ទី២អាចត្រូវស្លាប់ហើយចំពោះសត្វព្រៃនេះក៏មានការប៉ះពាល់ដែរ នៅពេលដែលយើងធ្វើទៅ ត្រូវរំខានដល់ការបំលាស់ទីវានៅតំបន់ដែលយើងត្រូវធ្វើ ហើយធ្វើឱ្យបាត់បង់ទីជំរកលាក់ខ្លួននិងការបន្តពូជរបស់វា។ ហេតុដូច្នេះបានជាយើងសុំឱ្យខាងក្រុមសរសេរ EIA ដូចយើងធ្វើកន្លងមកអញ្ជើងបញ្ចៀស ឬមួយយ៉ាងដូចម្តេច?កុំវាងាប់ព្រៃនេះឬយ៉ាងម៉េច ខ្ញុំជឿថាលោកអាចមានលទ្ធភាពសរសេរហើយដើម្បីដាក់ឱ្យក្រុមហ៊ុនអនុវត្តបាន ហើយដើម្បីអនុវត្តបានកាន់តែល្អជាងនេះទៀត EIA ត្រូវឱ្យមានមន្ត្រីទៅចូលរួមសហការ ក្នុងនោះខ្ញុំសុំឱ្យមានបរិស្ថាន ជលផល និងមេព្រៃ មិនមែនថាទៅដើម្បីកៀបក្រុមហ៊ុនយកលុយអីទេ ដើម្បីជួយសំរួល និងដាក់បន្ទាត់ឱ្យក្រុមហ៊ុននោះអនុវត្តតាមដូចមាននៅក្នុងសៀវភៅ EIA

ដែលបានរំចែង មើមិនដាក់ទៅទេ ធម្មតាក្រុមហ៊ុនមិនអនុវត្តតាមទេ អញ្ចឹងហើយដល់ពេលមានបញ្ហាប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ទើបគាត់មកហៅជំនាញ ដូច្នេះហើយទើបខ្ញុំឱ្យដាក់ទៅក្នុងរបាយការណ៍នេះហើយបញ្ជូនឱ្យបានចូលរួមតែម្តង មិនមែនដាក់គ្រាន់សរសេរដាក់ក្នុងសៀវភៅហើយអត់បញ្ជូននោះទេ។ ហើយការកំណត់ថ្លៃបង់លុយស្តារបរិស្ថានឡើងវិញនេះ គឺលុយថ្លៃសួយសារអាករទេ គឺគេហៅថា មូនិធិទ័យទានបរិស្ថាន( ស្តារបរិស្ថាននៅក្នុងតំបន់នោះឡើងវិញ) ហើយខ្ញុំសូមចូលរួមមានយោបល់តែប៉ុណ្ណេះ។

**បណ្ឌិត លី សុពណ៌_មុនី** : សូមអរគុណ ខ្ញុំចង់បង្ហាញជូននីតិវិធីសូមលើកឧទាហរណ៍ ដោយសារថា របាយការណ៍នេះពាក់កណ្តាលខែក្រោយទើបចប់ជាស្ថាពរ ខ្ញុំលើកយកវិធានការណ៍កាត់បន្ថយ ផលប៉ះពាល់បរិស្ថាន របស់គំរោងធ្វើអាជីវកម្មរ៉ែដែរ តែនៅវាលវែង ខេត្តពោធិ៍សាត់ ឧទាហរណ៍ថា តំលៃដែលគ្រោងសំរាប់ឧបត្ថមគំរោងតាមដានពិនិត្យវាយតំលៃពង្រឹងសមត្ថភាពប៉ាន់ស្មានថាអស់ ៧៨000ដុល្លារ នៅក្នុង១ឆ្នាំ ព្រោះគំរោងថវិកាគ្រោងសំរាប់ជួសជុល និងកែប្រែបរិស្ថាននៅក្នុងអាយុកាលនៃការធ្វើអាជីវកម្មរ៉ែ ត្រូវបានប៉ាន់ស្មានថាអស់ ១៣៧-១៤២លានដុល្លារ រ៉ែនេះវាមានសមធីសរុប១២លានតោន រ៉ែ១តោនមានតំលៃប្រហែលជិត ២000ដុល្លារ។ ដូច្នេះយើងមើល Turn over នៅក្នុងអាយុកាលគឺ៣0 ពាន់លានដុល្លារ ក្នុងបច្ចេកទេសបរិស្ថានរបស់យើងគាត់ធ្វើ Reference Presion គឺគាត់ធ្វើ Mine Closure បានន័យថាបិទរណ្តៅរ៉ែ ប៉ុន្តែរណ្តៅរ៉ែវាធំវានៅសល់រណ្តៅរ៉ែដូចជា ប៉ុន្មានពាន់ហិកតានៅលើដី ១ម៉ឺនហិកតា យើងមើលតំលៃវាសរុប១៣៧ ទៅ១៨២លានដុល្លា។ ហើយយើងមើលតើមានអ្នកណាខ្លះ ចូលរួម នេះតំលៃប៉ាន់សំរាប់អនុវត្តន៍ EMP មានន័យថា Enveronment Menagement Plane ផែនការ គ្រប់គ្រងបរិស្ថាន និងការត្រួតពិនិត្យតាមដានវាយតំលៃការអនុវត្តន៍វិធានការ យើងប្រើ pH ជាប៉ារ៉ាម៉ែត្រ សំរាប់វាស់ pH របស់ដី។ ចំពោះតំលៃសំរាប់ពិនិត្យរកលោហៈធ្ងន់ៗពួក HB Matal ស្ថិតក្នុងអំបូរអាសេនិច មើលទៅលើ COD & POD អស់ប៉ុន្មាន។ ការរៀបចំប្រពន្ធ័ធ្វើឱ្យទឹករង យើងនិយាយថា ជា Taling Inpatient System សំរាប់ស្តាត់ការហូរកករ ជាតិពុលផ្សេងៗ។ ការត្រួតពិនិត្យតាមដានជួលបុគ្គលិកអចិន្ត្រៃយ៍ចំនួន២នាក់ ដើម្បីបណ្តុះបណ្តាល ធ្វើជា Local Environment សំរាប់ប្រចាំការនៅក្នុងក្រុមហ៊ុន មន្ត្រីសមត្ថកិច្ចស្រុក និងខេត្ត ក្រុមប្រឹក្សាឃុំ៤នាក់ រយៈពេលប៉ុន្មានៗនេះជា Monitoring Programe មន្ត្រីបរិស្ថាន២នាក់ មន្ត្រីក្រសួងឧស្សាហកម្ម២នាក់ ស្ថាបន័ត្រួតពិនិត្យឯករាជ្យ២នាក់ រយៈពេល៣ថ្ងៃ ហើយ២ខែម្តង ចំណែកឯអចិន្ត្រៃយ៍រៀងរាល់ខែតែម្តង សមត្ថកិច្ចស្រុកពេលដែលក្រុមចំរុះពីភ្នំពេញចុះទៅសមត្ថកិច្ចស្រុក២នាក់ ប៉ុន្តែនៅជិតកំណត់ឱ្យ២ថ្ងៃ ក្រុមប្រឹក្សាឃុំ៤នាក់គិតឱ្យ២ថ្ងៃ មន្ត្រីក្រសួងបរិស្ថានពីភ្នំពេញមកចាំបាច់ត្រូវ៣ថ្ងៃ មន្ត្រីក្រសួងឧស្សាហកម្ម៣ថ្ងៃដែរ អ្នកចូលរួមមានប៉ុណ្ណឹង។ ការពង្រឹងសមត្ថភាពបុគ្គលិករបស់ក្រុមហ៊ុនបណ្តុះបណ្តាលឱ្យគាត់មានជំនាញជាប្រចាំ។ ការគ្រោងថវិកា ក្នុងការលុបរណ្តៅនៃអាយុកាលក្នុងការធ្វើអាជីវកម្ម ការលុបរណ្តៅមានតំលៃ៦៧លានដុល្លារ ការដាំឈើឡើងវិញគឺ ១ម៉ឺនដុល្លាក្នុង១ហិកតា។ ការឧបត្ថម្ភចំពោះអ្នករងគ្រោះតាមការជាក់ស្តែងក្រុមហ៊ុនចាំបាច់

Draft

ត្រូវមានថវិកាគ្រប់គ្រាន់ដើម្បីធ្វើការងារនេះ ។ ហើយនេះគ្រាន់តែជាការឆ្លើយត្រួស១ដើម្បីជូនខាងមន្ទីរបរិស្ថាន ។

**លោក ម៉ិន ឈើក អភិបាលស្រុកស្រែអំបិលៈ** ចំពោះ ខ្ញុំខាងអាជ្ញាធរដែនដី បើគំរោងមិនទាន់ចុះអនុវត្តទេ ផលប៉ះពាល់ជាក់ស្តែងចំពោះមុខមិនទាន់មាន ព្រោះខាងខ្ញុំនេះខាងសង្គម រីឯជំនាញបានលើកឡើងហើយ ផលប៉ះពាល់ព្រៃឈើយ៉ាងម៉េច ទឹកយ៉ាងម៉េច សត្វព្រៃនោះយ៉ាងម៉េចគឺខាងជំនាញ ខាងខ្ញុំឯណេះពាក់ពន្ធ័ជាមួយសង្គម មានន័យថាពាក់ពន្ធ័ជាមួយប្រជាពលរដ្ឋដែលរស់នៅក្បែរនឹង ហើយកន្លែងយករ៉ែនោះមិនទាន់មានប្រជាពលរដ្ឋទេ ដូច្នេះខ្ញុំមិនអាចវាយតំលៃយ៉ាងដូចម្តេចទេ បើមានគំរោង ដូចជាមានការឈូសឆាយផ្លូវត្រូវតែមានការប៉ះពាល់ហើយ ព្រោះវាមិនដែលធ្វើផ្លូវពីក្នុងមកត្រូវតែមានអ្នកខាងក្រៅចូល ដូច្នេះត្រូវតែមានការសិក្សាវាយតំលៃ ក្នុងដំណាក់កាលដំបូងខាងអាជ្ញាធរយើងខ្ញុំក៏មិនទាន់មានមតិអ្វីដែលត្រូវវាយតំលៃពីផលប៉ះពាល់ទេ។ ក្រុមហ៊ុននេះក៏មិនបានទំនាក់ទំនងអ្វីជាក់លាក់ជាមួយអាជ្ញាធរដែរ គ្រាន់តែជំរាបឱ្យដឹងថាបានមកសិក្សា គំរោងរ៉ែ ហើយតំបន់នោះមិនឱ្យអ្នកណាចូលទៅឬក៏ត្រួតពិនិត្យបានទេ។ ក្នុងនាមជាអាជ្ញធរមួយរយៈកន្លងមកគ្រាន់ត្រឹមតែបានដឹងទេ។ ចំពោះផលប៉ះពាល់គឺអាស្រ័យលើអ្នកសិក្សាវាយតំលៃ តើវាមានកំរិតប៉ុណ្ណា ទៅលើធនធានធម្មជាតិដូចជា ព្រៃឈើ សត្វព្រៃ មច្ឆាជាតិ ផ្សេង១ដែលរស់នៅក្នុងទឹកដូចខាងជំនាញបានលើកឡើង។ ដូចនេះ ខ្ញុំមិនមានយោបល់អ្វីបន្ថែមទៀតទេ សូមបញ្ចប់តែប៉ុណ្ណេះ ។

**លោក ឱ សាវុធ អភិបាលស្រុកថ្មបាំង :** ចំពោះស្រុកថ្មបាំង បើសិនជាវាយតំលៃផលប៉ះពាល់ជាសំខាន់អាជ្ញធរស្រុកមកនេះគឺ ពាក់ពន្ធ័សង្គមក៏ប៉ុន្តែដូចលោកអភិបាលស្រុកស្រែអំបិលបានលើកឡើងហើយបញ្ហាសង្គមគឺវាមិនប៉ះពាល់អ្វីធ្ងន់ធ្ងរនៅឡើយទេ ព្រោះបើតាមការបកស្រាយរបស់លោកបណ្ឌិតទីតាំងដែលក្រុមហ៊ុនសិក្សានេះវានៅឆ្ងាយពីទីប្រជុំជនរបស់ប្រជាពលរដ្ឋទាំងពីស្រុក ដូច្នេះការប៉ះពាល់វាមិនទាន់ជាធ្ងន់ធ្ងរប៉ុន្មានទេ។ នៅក្នុងករណីនេះខ្ញុំចង់មានយោបល់ចំពោះក្រុមហ៊ុនដែលចុះស្រាវជ្រាវរុករករ៉ែនៅអូរតាគុតនេះគឺខ្ញុំគ្រាន់ត្រដឹងតាមពណិមានទេ លិខិតអនុញ្ញាតពីក្រសួង ខ្ញុំបានទទួលម្តង ហើយក្រុមហ៊ុនចូលទៅសិក្សារុករកសំបុករ៉ែជាបន្ត១នេះ ខ្ញុំមិនបានដឹងទេ ដូច្នេះវាមានការដាច់ទំនាក់ទំនងរវាងក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន។ ជាសំណូមពរទៅមុខទៀតបើសិនជាក្រុមហ៊ុននោះចូលទៅតំបន់នោះវាស្ថិតនៅឆ្ងាយពីអាជ្ញាស្រុកទាំពីរឆ្ងាយគួរសមដែរ បើក្រុមហ៊ុនចូលបើមនមានការសហការជាមួយអាជ្ញធរស្រុក មានបញ្ហាអ្វីកើតឡើងឬមួយអសន្តិសុខនិងបញ្ហាអ្វីដែលមិនល្អ ដែលតំណាងក្រុមហ៊ុនចូលទៅតំបន់នោះគឺមិនល្អ ហើយអាជ្ញាធរធ្វើការអន្តរាគមន៍មិនទាន់ទេ ។ដូច្នេះជាសំណូមពររបស់ខ្ញុំ សូមឱ្យក្រុមហ៊ុនទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានបានចុះទៅជាមួយផង .បើមើលទៅលើផែនទីក្រុមហ៊ុនច្បាស់ជាងអ្នកស្រុកហើយ ប៉ុន្តែបើភូមិសាស្ត្រជាក់ស្តែងអ្នកស្រុកវិញ ហេតុនេះសូមឱ្យក្រុមហ៊ុនទំនាក់ទំនងឱ្យបានចូលទៅតំបន់នោះសុវត្ថិភាពទាំងអស់គ្នា ការពារកុំឱ្យមានអសន្តិសុខនៅក្នុងតំបន់ផង ការពារសុវត្ថិភាពឱ្យក្រុមហ៊ុនផង ។ ចំពោះបញ្ហាមួយទៀតពាក់ពន្ធ័ និងឈើមានចំជំនាញអ្វីខ្ញុំទេ កន្លង

Draft

មកខ្ញុំធ្លាប់ចូលរួមសិក្ខាសាលា នៅថ្នាក់ជាតិក្រុមហ៊ុនវ៉ារីអគ្គិសនី បើក្រុមហ៊ុននេះយកឈើចេញដូចក្រុមហ៊ុនវ៉ារីអគ្គិសនីវាមិនពិបាកអ្វីទេ។ យើងធ្វើការដេញថ្លៃ ដូចក្រុមហ៊ុនវ៉ារីអគ្គិសនីគេដេញថ្លៃមុននឹងធ្វើទំនប់ គឺឈើទាំងអស់នៅក្នុងអាងទំនប់ត្រូវការ ដាក់ឱ្យដេញថ្លៃយកចេញទាំងអស់។ ក្រុមហ៊ុនយករ៉ែក៏នេះក៏ដូច្នេះដែរបើត្រូវការយកឈើចេញទាំងអស់ក្នុងតំបន់នោះធ្វើការដេញថ្លៃទៅ តើត្រូវដោះស្រាយឈើនោះរបៀបដូម្តេចដែលក្រុមហ៊ុនបានសម្បទាននូវទំហំដីនឹង នេះជាយោបល់របស់ខ្ញុំដែលធ្លាប់បានចូលរួមសិក្ខារបស់ក្រុមហ៊ុនវ៉ារីអគ្គសនីទាំងពីនៅស្រុកថ្មបាំង។ ចំពោះបញ្ហាដែលទាំងទងទៅនឹងការឈូសផ្លូវចូលទៅតំបន់នោះ ទី១វាមានផ្លូវលំចាស់ដែលមាន ទី២មិនអាចមានផ្លូវលំនឹងទេដោយសារយើងចោលយូរឆ្នាំឈើវាដុះឡើងវិញអស់ ដូច្នេះវាត្រូវបាត់អស់ផ្លូវលំចាស់ ដូច្នេះការធ្វើឈូសឆាយផ្លូវដែលចូលទៅគឺថ្មីទាំងអស់បញ្ហាព្រៃឈើជៀសមិនផុតមួយវិញទៀតបញ្ហាជាមួយប្រជាពលរដ្ឋ កាលណាមានផ្លូវតែងតែមានប្រជាពលរដ្ឋទៅយកដីនៅតាមផ្លូវនឹងប៉ុន្តែចំណុចសំខាន់យើងទំនាក់ទំងជាមួយអាជ្ញាធរ ខេត្ត ស្រុក ឃុំ ធ្វើការគ្រប់គ្រងឱ្យច្បាស់ទៅគឺមិនអាចទៅចាប់អានាធិបតេយ្យបានទេ ខ្ញុំជឿជាក់ថាអញ្ចឹង។

**លោក ហ៊ត់ សុគន្ធ** មន្ត្រីសម្របសម្រួល អង្គការសម្បត្តិសត្វព្រៃ : សូមថ្លែងអំណរគុណដល់ឯកឧត្តម អភិបាលរងខេត្ត ដែលបានផ្តល់ឱកាស នៅក្នុងការពិភាក្សាពិគ្រោះយោបល់ក្នុងថ្ងៃនេះ និងក្រោយពីបាន ស្តាប់បទបង្ហាញអំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់បណ្ឌិត **លី សុពណ៌-មុនី** ចំណែកខាងខ្ញុំ នៅពេលនេះមិនបញ្ហាអ្វីដែលត្រូវចូលរួមនៅក្នុងពិភាក្សានេះទេ ហើយក៏មិនមានសិទ្ធសំរេចជាយោបល់អ្វីដែរ ដោយសារប្រធានអង្គការគាត់មានធុរៈជាប់រវល់ពុំអាចមកបាន ដូច្នេះខាងខ្ញុំសុំទិន្នន័យដើម្បីយកទៅវិភាគឱ្យស៊ីជំរៅ ហើយផ្តល់ជូនជាយោបល់ និងចម្លងជូនគ្រប់ស្ថាប័នពាក់ពន្ធ័ដើម្បីបានជ្រាបជាពតិមាន។

**បណ្ឌិត លី សុពណ៌-មុនី :** ពាក់ពន្ធ័ទៅនឹងទិន្ន័យទាំងអស់ ដូចខ្ញុំបានជំរាបខាងដើម គឺមុនឬក្រោយពាក់ណ្តាលខែក្រោយអាចចប់សព្វជាស្ថាពរ ព្រោះខ្ញុំត្រូវបញ្ជូនក្រុមការងារ២ចុះទៅទៀត ដោយសារបញ្ហាអាកាសធាតុ យើងមិនអាចធ្វើការងារនេះបាន។ ដូច្នេះទិន្ន័យរបស់យើងនៅដើមខែ១០ ឬដើមខែ១១យើងអាចបញ្ចប់។ ក្រុមការងារ១ក្រុម ដើរចូលទៅក្នុងព្រៃដើម្បីពិនិត្យ Diversity ដែលមាននៅក្នុងដីដែលក្រុមហ៊ុនស្នើសុំវិនិយោគ ឯក្រុមការងារទី២ ក្រុមហោះពិនិត្យមើលគំរបព្រៃពីលើអាកាសដោយប្រើឧបករណ៍ភារាម្យត្យរ ដើម្បីដឹងថា ក្នុងតំបន់ដែលត្រូវរុករករ៉ែនោះមានគំរបព្រៃនៅសេសសល់ប៉ុន្មានភាគរយ។

**ឯកឧត្តម សុន តារា អភិបាលរងខេត្ត :** ពាក់ពន្ធ័នឹងការស្នើសុំរបស់គំរោងសំណាងរ៉ែ ត្បូងថ្មទី១យោងស្មារតីអង្គប្រជុំថ្ងៃនេះគឺជាការសោកស្តាយណាស់ដែលក្រុមហ៊ុនគ្រីនត្រូវសិក្សាបន្តទៅទៀតនោះគឺថាដើម្បីធានាបានសន្តិសុខ សុវត្ថិភាព ពាក់ពន្ធ័នឹងការសិក្សាដើម្បីឱ្យអាជ្ញាធរបានដឹងផង ពេលដែលយើងបញ្ចប់នៅខែក្រោយ១ទៀត សូមមេត្តាឱ្យមានអង្គភាពជំនាញ ចូលរួម ជាសំខាន់បំផុត អភិបាលស្រុក មេឃុំ ទី១បាន



Draft

ឱ្យដឹងពតិមានផង ទី២ការពារសុត្ថិភាព ព្រោះតំបន់នោះជាព្រៃដាច់ស្រយាលណាស់ ហើយវាមានសត្វកាចសាហាវច្រើន។ ទី២ខាងរដ្ឋបាលព្រៃឈើមេត្តាផ្តល់នូវសំណូមពរ អ្វី១មកខេត្តឱ្យបានដឹងអំពីគោលបំណងហើយនឹងផ្តល់យោបល់អំពីហេតុប៉ះពាល់បរិស្ថាន ដើម្បីដាក់ជូនទៅក្រសួង និងអន្តរក្រសួង។ ហើយខ្ញុំក៏សូមបញ្ជាក់បន្ថិចចំពោះការធ្វើវារីអគ្គិសនីនៅស្ទឹងអារ៉ែងក៏យើងនិយាយអំពីគំរបឈើព្រៃនេះដែរ ក្រែងលោតំបន់នឹងពាក់ពន្ធ័យ៉ាងណាដើម្បីឱ្យអង្គភាពជំនាញនៅក្នុងខេត្ត អាជ្ញាធរក្នុងខេត្តបានដឹង អាចជួយឬមួយយ៉ាងម៉េច តែនេះគ្រាន់តែជាឧទាហរណ៍។ នេះយើងមិនទាន់បានសរសេរឱ្យបានវែងឆ្ងាយ ហើយបើសរសេរមួយថ្ងៃដល់ល្ងាចមិនទាន់ចប់ទេ។ ដូច្នេះក្រោយពេលក្រុមហ៊ុន ហ្វ្រីនេះធ្វើការសិក្សាចប់ គឺយើងត្រូវយកកំណត់ហេតុរបាយការណ៍វាយតំលៃហេតុ ប៉ះពាល់បរិស្ថាននេះ មកដាក់នៅសាលាខេត្តប្រជុំជាចុងក្រោយ មុននឹងដាក់ទៅអន្តរក្រសួង អំពីមតិយោបល់គ្រប់អង្គភាពដែលមាននៅលើទឹកដីខេត្តកោះកុង ឱ្យបានដឹងអំពីគំនិតយោបល់គ្រប់អង្គភាពដែលបានលើកមកហើយ ខ្ញុំគ្រាន់តែទៅចូលរួមស្តាប់បទបង្ហាញនៅអន្តរក្រសួង ហើយសុំឱ្យក្រុមហ៊ុនហ្វ្រីនចុះសិក្សាបញ្ចប់នឹងដាក់ប្រជុំម្តងទៀត ដើម្បីចង់ក្រងជាសៀវភៅឱ្យបានច្បាស់លាស់សំរាប់ក្រុមហ៊ុនអនុវត្តតាម។ ជាទីបញ្ចប់នេះខ្ញុំសូមថ្លែងអំណគុណចំពោះ បណ្ឌិត លី សុពណ៌-មុនី ដែលមានស្នាដៃ ក្នុងការសរសេរដែលគេទទួលស្គាល់ច្រើន និង សូមថ្លែងអំណគុណដល់អស់លោកជាប្រធានមន្ទីរស្ថាប័នជំនាញ ជាពិសេសលោកអភិបាលស្រុកទាំងពីរ( ស្រែអំបិល និងស្រុកថ្មបាំង) និងសមាជិកទាំងអស់ដែលបានចូលរួមបញ្ចេញមតិយ៉ាងក្បោះក្បាយនៅក្នុងបទបង្ហាញ លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់ក្រុមហ៊ុនសំណាងរ៉ែ ត្បូងថ្ម។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១០:៣០ នាទីរសៀល នៅថ្ងៃ ខែ ឆ្នាំ ដដែលក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងយោគយល់គ្នាខ្ពស់។

ធ្វើនៅកោះកុង,ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៩

អ្នកធ្វើកំណត់ហេតុ

ហត្ថលេខា



Draft

## REFERENCES


1. A Poverty Profile of Cambodia, MoP, 1997
2. Asia-Pacific Tropical Forestry: Ecological Disaster or Sustainable Growth, RAPA, Bangkok, 1994
3. Agricultural Strategies and Policy Framework for Sustainable Food Security and Poverty Alleviation, Cambodia, May 2000
4. Barney.L, Steven.R.S, and Kry.M. 2000. Biological Survey in Northeast Modulkiri. Cambodia.
5. Biodiversity the Life of Cambodia. Edited by Jady Smith, 2001
6. Cambodia Poverty Assessment, MoP, 1999
7. Cambodia Forestry Code of Practice for Harvesting dated 26 July 1999
8. Charles.M.F. 2008. A Guide to the Mammals of Southeast Asia. Princeton University Press. Princeton and Oxford.
9. Chhang.P. 2009. Plant Diversity of Cambodia. Unpublished data. The Forestry Administration. Cambodia.
10. Conflict and Natural Resource Management, FAO, 2000
11. David.D, Matthew.F, Grahan.T, Michael.S, and Philip.S. 2005. Handbook of Biodiversity Methods. Survey, Evaluation and Monitoring. Cambridge University Press.
12. Dy Phon.P. 2000. Dictionary of Plant use in Cambodia. Imprimerie Olympic. Cambodia.
13. Edward.P, Tom.C, Nut.M.H, Sok.S, and Benjamin.R. 2007. Status and Conservation of Globally Threatened Primate in the Seima Biodiversity Conservation Area, Cambodia. Wildlife Conservation Society. Cambodia Programme.
14. FAO Model Code of Forest Harvesting Practice, Rome 1995
15. FAO Model Code of Forest Harvesting Practice, Rome 1996
16. Forest Concession Management Planning Manual, dated March 2001
17. Forest Inventory in Eastern Mekong by B. Rollet 1962
18. Forest Resources Assessment 1990, in Tropical Countries, FAO, Rome, 1993
19. Forestry Administration. 2007. Cambodia Forest Statistics 2006. Forestry Administration, Cambodia.
20. General Population Census of Cambodia – Final Census Result of 1998
21. Gene-Ecological Zonation of Cambodia – Forestry Administration, DANIDA, German Development Services, December, 2003
22. Guidelines For Preliminary EIA for Forest Harvesting – 27 January 1995
23. Handbook of the Policy and Basic Procedure of EIA in Sarawak – 27 January 1995
24. Hostetler, M.E, and Main, M.B. 2001. Florida morning program: point count method to survey birds. University of Florida, Institute of food and agriculture science.
25. Joe.W, Peter.D, and Men.S. 2001. A Wildlife Survey of Southern Mondulkiri Province, Cambodia. Wildlife Conservation Society. Cambodia Programme.
26. Landuse Capability Map 1997/97
27. Masphal.K , Shin.J. R, Seung.H.S, Eun.J.L, Woo.S.L, and Bunnat.P. 2009. Differences in Bird Communities Between Before and After Forest Fire in Tropical Lowland *Dipterocarp* forest of the Northeastern Cambodia.
28. Masphal.K, Woo.S.L, Sung.J.P, and Shin.J.R. 2009. Bird Community in Ricefield and Grassland during the Dry Season in the Mekong Delta, Cambodia. Journal of Korean Forest Society.
29. Mondulkiri Province. 2005. Announcement of prohibitions and demarcation of Mondulkiri protected forest. Mondulkiri Province, Cambodia.
30. Megan.M. 2007. Burning Issue. WWF Greater Mekong. Cambodia Country Programme.
31. Men.S, Soun.P, Sin.P, and Joe.W. 2008. A Field Guide to Mammals of Cambodia. Forestry Administration, WCS, Cambodia.
32. Ministry of Agriculture, Forestry, and Fisheries (MAFF). 2007. Prakas on Classification and List of Wildlife Species. Cambodia.
33. Merel.J.C, Peter.P.V.D, Jarujin.N, and Kumthorn.T. 1998. Snakes and Other Reptiles of Thailand and Southeast Asia. Asia Books.co.,ltd. Thailand.
34. Ministry of Environment (MoE). 2002. Cambodia initial nationalcommunication. Under the united nation convention framework on climate change. Phnom Penh Cambodia.
35. National Environmental Planning Manual 1998-2002


Draft

36. National Forest Policy of Cambodia, WB, UNDP, FAO, April 1996
37. National Weather Report From Ministry of Water Resource and Meteorology
38. Nicholas.B, Kry.M, Karin.V, Catriona.C, and Richard.T. 2009. Western Siem Pang Forest Carbon Project. Pilot study of carbon stocks and project feasibility. Ecometrica. UK.
39. Non-wood Forest Products for Rural Income and Sustainable Forestry, FAO, Rome, 1995
40. Peason.T, Walker.S, and Brown.S. 2005. Sourcebook for Land Use, Land Use Change and Forest Project. Winrock International.
41. Prum.S. and Tom.G. 2009. Research and monitoring activities in Mondulkiri Protected Forest. Unpublished data. WWF Cambodia.
42. Sarah.W, Timothy.P, Nancy.H, Ken.M, and Sandra.B. 2009.Terrestrial Carbon Measurement Standard Operating Procedures. Winrock International, Ecosystem services.
43. Schweithelm, J. and H.K. Chhay. 2007. Mondulkiri protected forest: management plan 2008 - 2012. Forestry Administration, Kingdom of Cambodia, Phnom Penh.
44. Sub-Decree on the declaration of Protected Areas dated 1st November 1993
45. Satellite Imageries map interpreted by DFW year 1996/97/2000
46. Strategic Environmental Framework for the Greater Mekong Sub-region: Integrating Development and Environment in the Transport and Water Resource Sectors, Stockholm Environment Institute
47. Soil Survey Report of Charles D. Crocker 1962/63
48. Tan.S, and Colin.P. 2008. A Field Guide to the Birds of Cambodia. Wildlife Conservation Society. Cambodia Programme.
49. Tran.T.C, and Kol.T. 1995. Soil and Vegetation of Cambodia (in khmer). Department of Forestry and Wildlife. Cambodia.
50. The Atlas of Cambodia, National Poverty and Environmental Maps, DANIDA, 2006
51. Vegetation of Cambodia 1972 & 1996/97 and 2000


Draft